# លទ្ធផលនៃការសង្កេតដោយសង្ខេប

របាយការណ៍ឆមាសលើកទី២ នីតិកាលទី៥ នៃរដ្ឋសភា (ខែមករា ដល់ខែមិថុនា ឆ្នាំ២០១៥) ការសង្កេតឃើញថា សកម្មភាពរបស់គណៈកម្មការជំនាញរដ្ឋសភា និងចំនួនសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានភាពល្អប្រសើរជាងរយៈពេលដូចគ្នាក្នុងដើមនីតិកាលនេះ។ ផ្ទុយទៅវិញការពិភាក្សា និងអនុម័តច្បាប់ហាក់មិនសូវមានគុណភាព និងធ្វើឡើងដោយប្រញាប់ប្រញាល់។

នៅក្នុងរបាយការណ៍ឃ្លាំមើលរដ្ឋសភា និងតំណាងរាស្ត្រនេះមានលើកមកបង្ហាញដូចជា៖ ដំណើរការប្រជុំរបស់រដ្ឋសភា សកម្មភាពសំខាន់ៗរបស់គណៈកម្មការជំនាញរដ្ឋសភា សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ដំណើរការអគ្គលេខាធិការដ្ឋានរដ្ឋសភា កិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា និងព្រឹត្តិការណ៍សំខាន់ៗទាក់ទងរដ្ឋសភា និងតំណាងរាស្ត្រ។

**ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រៈ** តាមរយៈទិន្នន័យដែលខុមហ្វ្រែលទទួលបាន មានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានចំនួន៦១២លើក ដែលក្នុងនោះ សកម្មភាពរបស់អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួន៥២៧លើក និងគណបក្សប្រជាជនកម្ពុជាចំនួន ៨៥លើក។ បើប្រៀបធៀបក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំទី១ នៃនីតិកាលទី៥នេះ ការសង្កេតឃើញថា ចំនួនសកម្មភាពមានការកើនឡើង ប៉ុន្តែចំនួនតំណាងរាស្ត្រធ្វើសកម្មភាពមានការថយចុះតិចតួច ដែលក្នុងរយៈពេលនោះមានតំណាងរាស្ត្រចំនួន៧៤រូប ចុះធ្វើសកម្មភាពបានចំនួន៤០០លើក។ មូលហេតុសំខាន់នៃការកើនឡើងនៃចំនួនសកម្មភាព ជាពិសេសតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិព្រោះថា ក្រុមតំណាងរាស្ត្រទាំងនោះបានចូលរដ្ឋសភា ដែលបង្កលក្ខណៈងាយស្រួលក្នុងការធ្វើសកម្មភាពជាងក្នុងនាមជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ។

ក្នុងចំណោមសកម្មភាពចុះមូលដ្ឋានក្នុងអំឡុងពេលនេះ គឺមានតំណាងរាស្ត្រ ចំនួន៧០រូប ដែល៣៨រូប ពីគណបក្សប្រជាជនកម្ពុជា និង៣២រូប ពីគណបក្សសង្គ្រោះជាតិ ដោយបានធ្វើសកម្មភាពសរុប ៦១២លើក លើគោលបំណងចំនួន៥ រួមមាន ១.ការចុះសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយប្រជាពលរដ្ឋ និងការសម្ពោធសមិទ្ធិផលនានា ២.ការចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្ស ៣.ការចូលរួមវេទិកាសាធារណៈ ៤.ការអមដំណើរថ្នាក់ដឹកនាំ និង៥.ការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាក្នុងគោលបំណងជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ រួមទាំងសម្ពោធសមិទ្ធិផលនានាចុះបានចំនួន ៤៨លើក អមដំណើរថ្នាក់ដឹកនាំបានចំនួន២៧លើក ចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សបានចំនួន ០៧លើក ចូលរួមវេទិកាសាធារណៈចំនួន០២លើក និងជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាចំនួន ០១លើក។ រីឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ការចុះមូលដ្ឋានក្នុងគោលបំណងជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋចំនួន ៣៣១លើក ចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សបានចំនួន ៧៧លើក អមដំណើរថ្នាក់ដឹកនាំគណបក្សចំនួន ៨៦លើក ជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាបានចំនួន ២២លើក និងចូលរួមវេទិកាសាធារណៈបានចំនួន ១១លើក។

**សកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភាៈ** សកម្មភាពរបស់គណៈកម្មការជំនាញមានការកើនឡើងគួរឲ្យកត់សម្គាល់ទាំងគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលក្នុងរយៈពេលនេះមានសកម្មភាពរហូតដល់ ៤៥លើក។ រដ្ឋមន្ត្រីចំនួន ៨រូប ត្រូវបានហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញ

**មាតិកាសំខាន់ៗ**


I. ដំណើរការប្រជុំរបស់រដ្ឋសភា ទំព័រទី ៣

II. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ទំព័រទី ៨

III. ដំណើរការអគ្គលេខាធិការដ្ឋានរដ្ឋសភា និងកិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា ទំព័រទី ១៣

IV. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ ទំព័រទី ១៥


រដ្ឋសភា និងនៅក្នុងក្រសួងសាមី។ គួរបញ្ជាក់ថា សកម្មភាពដែលខុមហ្វ្រែលបានរាប់បញ្ចូលរួមមាន ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ សកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬ/និងប្រជាពលរដ្ឋ ឬតំណាងអង្គការសង្គមស៊ីវិល និងព្រមទាំងសកម្មភាពចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ។

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា:** រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញ១លើក និងវិសាមញ្ញ១លើក ដែលមានកិច្ចប្រជុំសរុបចំនួន ១០លើក។ របៀបវារៈចំនួន១៥ ត្រូវបានរដ្ឋសភាលើកមកពិភាក្សា និងអនុម័ត ហើយក្នុងនោះរួមមានការបោះឆ្នោតជ្រើសតាំងសមាជិក គ.ជ.ប និងសមាជិកគណៈកម្មការជំនាញរដ្ឋសភា។

ក្នុងចំណោមកិច្ចប្រជុំទាំងនោះ មានអ្នកតំណាងរាស្ត្រចំនួន ២៧រូប បានឡើងមកបញ្ចេញមតិ ដោយប្រើប្រាស់ថេរវេលាសរុប៥៥០នាទី។ អំពីគុណភាពនៃការពិភាក្សាវិញ ការសង្កេតឃើញថា ហាក់មិនសូវមានគុណភាព និងធ្វើឡើងដោយប្រញាប់ប្រញាល។ ជាក់ស្តែងដូចជាការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយមានតែតំណាងរាស្ត្រម្នាក់គត់គឺលោក សម រង្ស៊ី បានឡើងបញ្ចេញមតិ។ ខ្លឹមសារនៃការបញ្ចេញមតិផ្តោតលើការសរសើរអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារតាក់តែងច្បាប់របស់គណបក្សទាំងពីរ ហើយអ្វីដែលគួរឲ្យចាប់អារម្មណ៍ទៀតនោះគឺការស្នើមិនឲ្យអ្នកតំណាងរាស្ត្រផ្សេងទៀតឡើងបញ្ចេញមតិយោបល់។ វាជាបទពិសោធន៍មិនល្អមួយ ដែលប្រធានក្រុមមតិភាគតិចនៃរដ្ឋសភាបានស្នើឡើងបែបនេះ ព្រោះថាវាផ្ទុយពីគោលបំណងនៃកិច្ចប្រជុំរដ្ឋសភា ដែលអ្នកតំណាងរាស្ត្រគួរធ្វើការពិភាក្សា សួរដេញដោល និងឈានទៅការស្នើឲ្យមានកែសម្រួល ឬធ្វើការបកស្រាយនូវខ្លឹមសារមួយមិនច្បាស់លាស់ព្រោះថា សេចក្តីស្នើច្បាប់ទាំងពីរនេះ មានចំណុចអវិជ្ជមានមួយចំនួនដែលភាគីពាក់ព័ន្ធបានស្នើឲ្យអ្នកតំណាងរាស្ត្រធ្វើការកែសម្រួល។

សេចក្តីព្រាងច្បាប់ចំនួនពីរ ត្រូវបានអនុម័តមានសំឡេងតែមួយគណបក្សគឺគណបក្សប្រជាជនកម្ពុជា ហើយសេចក្តីស្នើច្បាប់សំខាន់ចំនួនពីរ ត្រូវបានអនុម័តដោយមិនមានការពិភាក្សាលើខ្លឹមសារច្បាប់។ ដោយឡែកការពិភ្សា លើសេចក្តីព្រាងច្បាប់ដ៏ចម្រូងសម្រាសស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិបានដើរតួនាទីដូចអ្នកការពារច្បាប់គឺធ្វើការពន្យល់នូវចំណុចវិជ្ជមាននៃសេចក្តីព្រាងច្បាប់ នៅស្របពេលដែលមជ្ឈដ្ឋានជាតិ និងអន្តរជាតិធ្វើការរិះគន់ថា ច្បាប់នេះបានរិតត្បឹតសិទ្ធិ សេរីភាពរបស់អង្គការ សមាគមមិនមែនរដ្ឋាភិបាល។

**ការចេញលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ:** ក្នុងរយៈពេលនេះ ការសង្កេតឃើញថា មានលិខិតរបស់អ្នកតំណាងរាស្ត្រចំនួន២២ច្បាប់ បានផ្ញើទៅស្ថាប័ននីតិប្រតិបត្តិ និងគណៈកម្មការរបស់រដ្ឋសភាក្នុងគោលបំណងស្នើវិធានការ/អំពាវនាវដើម្បីចាត់វិធានការ ឬ/និងអន្តរាគមន៍ទៅលើបញ្ហានានារបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ ក្នុងចំណោមលិខិតទាំង២២ច្បាប់នោះ ខុមហ្វ្រែលបានទទួលព័ត៌មានថា មានលិខិតចំនួន៤ច្បាប់ ទទួលការឆ្លើយតបពីរាជរដ្ឋាភិបាល។ ជាមួយគ្នានេះមានលិខិតចំនួន៣ច្បាប់ ត្រូវបានបដិសេធមិនធ្វើការបញ្ជូនដោយប្រធានរដ្ឋសភាផងដែរ ដែលករណីនេះត្រូវបានពិនិត្យឃើញថា ជាការប្រើសិទ្ធិអំណាចជាប្រធានរដ្ឋសភាហួសព្រំដែន។

ជាលើកទី១ ក្នុងអាណត្តិទី៥នេះ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមណ្ឌលខេត្តរតនគីរី បានចេញលិខិតអន្តរាគមន៍ស្នើដកតំណែងអភិបាលក្រុងបានលុង ដែលជាមន្ត្រីមកពីគណបក្សដូចគ្នា ក្រោយមានការប្តឹងពីប្រជាពលរដ្ឋករណីប្រើអំណាចបំពានលើប្រជាពលរដ្ឋ។

# អំពីរដ្ឋសភា និងតំណាងរាស្ត្រ

## I. ដំណើរការប្រជុំរបស់រដ្ឋសភា[1]

រដ្ឋសភានីតិកាលទី៥ ក្នុង១ឆមាស ដើមឆ្នាំទី២ ចន្លោះពេលពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៥ បានបើកសម័យប្រជុំពេញអង្គសាមញ្ញ១លើក ក្នុងចន្លោះពេលពីខែមេសា ដល់ដើមខែកក្កដា ឆ្នាំ២០១៥ និងបានបើកកិច្ចប្រជុំជាវិសាមញ្ញ១លើក ក្នុងចន្លោះខែមករា ដល់ខែមេសា ឆ្នាំ២០១៥ ដែលមានកិច្ចប្រជុំសរុបចំនួន១០កិច្ចប្រជុំ ដោយមួយកិច្ចប្រជុំមានរយៈពេលមួយព្រឹក។ អំឡុងពេលនេះ រដ្ឋសភាមានរបៀបវារៈចំនួន១៥ របៀបវារៈដែលតម្រូវយកមកពិភាក្សា និងអនុម័ត និងរួមទាំងបោះឆ្នោតជ្រើសតាំងសមាជិក គ.ជ.ប និងសមាជិកគណៈកម្មការជំនាញរដ្ឋសភា។

ក្នុងរបៀបវារៈទាំង១៥ រដ្ឋសភាយកមកពិភាក្សា និងអនុម័តនោះរួមមាន សេចក្តីស្នើច្បាប់ចំនួន០៣ច្បាប់ ដូចជា សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសេចក្តីស្នើច្បាប់ស្តីពីភតិកិច្ចសន្យាពិសេស។

សេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣ និងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

វិសោធនកម្មច្បាប់ចំនួន៣ច្បាប់ រួមមានច្បាប់ស្តីពីវិសោធនកម្មមាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣,៤,៥,២៦,២៧,២៨,៤២,៧៤ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនីនៃ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៧។

ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភាមានចំនួន០៥លើក រួមមាន ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន ១លើក និងការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការជំនាញនៃរដ្ឋសភាចំនួន ៤លើក។

### ១.១ ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា

#### ១.១.១ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ

ខ្លឹមសារនៃការបញ្ចេញមតិតំណាងរាស្ត្រ ក្នុងដើមឆមាសទី១ នៃឆ្នាំទី២ នីតិកាលទី៥នេះ ការអង្កេតឃើញថា ការឡើងបញ្ចេញមតិពិភាក្សារបស់តំណាងរាស្ត្រ គណបក្សទាំងពីរដែលមានអាសនៈនៅរដ្ឋសភាផុសផុល បើធៀបទៅនឹងដើមឆមាសនៃឆ្នាំទី១។ ក្នុងរយៈពេលនេះ ការឡើងបញ្ចេញមតិអ្នកតំណាងរាស្ត្រមានការកើនឡើង ដោយមានអ្នកតំណាងរាស្ត្រចំនួន២៧រូប មកពីគណបក្សជាប់ឆ្នោតទាំងពីរបានឡើងមកបញ្ចេញមតិយោបល់ ដោយប្រើប្រាស់ថេរវេលាសរុប៥៥០នាទី (៩ម៉ោង ១០នាទី)។ ការបញ្ចេញមតិនេះបើគិតជាមធ្យមក្នុងតំណាងរាស្ត្រម្នាក់ឡើងបញ្ចេញមតិចំនួនប្រមាណ ២០នាទី។

[1] សម័យប្រជុំរដ្ឋសភាសាធារណៈលើកទី ៤ បន្តរហូតដល់ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥ លើស ០៦ថ្ងៃនៃកាលបរិច្ឆេទបិទសម័យប្រជុំ។

គណបក្សប្រជាជនកម្ពុជាមានអាសនៈ៦៨ នៃអាសនៈក្នុងរដ្ឋសភា មានតំណាងរាស្ត្រ១៦រូប ឡើងបញ្ចេញមតិសរុបចំនួន៣៨៤នាទី (ស្មើនឹង០៥ម៉ោង៤៤នាទី)។ រីឯគណបក្សសង្គ្រោះជាតិដែលមានអាសនៈ៥៥ នៃអាសនៈក្នុងរដ្ឋសភា មានតំណាងរាស្ត្រចំនួន១១រូប ឡើងបញ្ចេញមតិសរុបចំនួន២០៦នាទី (ស្មើនឹង០៣ម៉ោង២៦នាទី)។

ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ និងគោលជំហររបស់តំណាងរាស្ត្រម្នាក់ៗ មាននិន្នាការស្របទៅនឹងបន្ទាត់នយោបាយរបស់គណបក្សខ្លួន។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សកាន់អំណាចភាគច្រើន តែងតែបញ្ចេញមតិការពារ ឬក៏កោតសរសើរគាំទ្រនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ រីឯគណបក្សប្រឆាំងវិញ តែងតែរិះគន់នូវចន្លោះគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការសង្កេតជាទូទៅឃើញថា មានតំណាងរាស្ត្រភាគច្រើន ដែលមិនបានឡើងបញ្ចេញមតិពិភាក្សាលើច្បាប់ដោយស្ថិតនៅក្នុងស្ថានភាពស្ងប់ស្ងាត់ មិនសូវមានការបញ្ចេញមតិយោបល់ក្នុងការពិភាក្សានោះទេ។

### ១.១.២ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ

ខ្លឹមសារមតិរបស់អ្នកតំណាងរាស្ត្រដែលបានបញ្ចេញនៅក្នុងអំឡុងពេលប្រជុំពេញអង្គ ត្រូវបានវិភាគដោយបែងចែកជាបីសូរ(Tone) គឺៈ អព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមាន ចំពោះស្ថាប័ន របៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយដែលអ្នកតំណាងរាស្ត្រនិយាយសំដៅទៅ។ ខ្លឹមសារអព្យាក្រឹត្យគឺសំដៅលើមតិធម្មតាទៅលើតួអង្គ ឬស្ថាប័នណាមួយ។ ចំណែកឯវិជ្ជមាន គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិសេចក្តីព្រាងច្បាប់គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ។ រីឯអវិជ្ជមានវិញ គឺនិយាយពីគុណវិបត្តិរបស់តួអង្គ ឬស្ថាប័នណាមួយ។

រយៈពេលរបាយការណ៍នេះ មានតំណាងរាស្ត្រចំនួន២៧រូប បញ្ចេញមតិចំនួន៥៥០នាទីស្មើនឹង(៩ម៉ោង១០នាទី)នៃតំណាងរាស្ត្រសរុបចំនួន១២៣រូបនៃរដ្ឋសភា ផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យ និងវិជ្ជមាននៃការបញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំ។ ក្នុងនោះខ្លឹមសារបែបអព្យាក្រឹត្យមានចំនួន៤៤៣នាទី (ស្មើនឹង៨ម៉ោង២៥នាទី) និងវិជ្ជមានមាន ចំនួន៩៧នាទី (ស្មើនឹង១ម៉ោង៣៧នាទី) ចំណែកខ្លឹមសារអវិជ្ជមានមាន ចំនួន១០នាទីប៉ុណ្ណោះ។

នាសម័យប្រជុំសភាជាវិសាមញ្ញលើកទី៣ ប្លែកពីកិច្ចប្រជុំពិភាក្សា និងអនុម័តច្បាប់កន្លងមក ពោលគឺការពិភាក្សា និងអនុម័ត សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយមានតែតំណាងរាស្ត្រម្នាក់គត់ គឺលោក សម រង្ស៊ី បានឡើងបញ្ចេញមតិដោយប្រើថេរៈវេលាចំនួន០៥នាទីប៉ុណ្ណោះ លើរបៀបវារៈទាំងពីរនេះ។ ខ្លឹមសារនៃការបញ្ចេញមតិផ្តោតលើការសរសើរអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារតាក់តែងច្បាប់ របស់គណបក្សទាំងពីរ ហើយអ្វីដែលគួរឲ្យចាប់អារម្មណ៍ទៀតនោះ គឺការស្នើមិនឲ្យអ្នកតំណាងរាស្ត្រផ្សេងទៀតឡើងបញ្ចេញមតិយោបល់។ ត្រង់ចំណុចនេះត្រូវបានមើលឃើញថា ជាបទពិសោធន៍មិនល្អមួយដែលប្រធានក្រុមមតិភាគតិចនៃរដ្ឋសភាបានស្នើឡើងបែបនេះ ព្រោះថាវាផ្ទុយពីគោលបំណងនៃកិច្ចប្រជុំរដ្ឋសភា ដែលអ្នកតំណាងរាស្ត្រគួរធ្វើការពិភាក្សា សួរដេញដោល និងឈានទៅការស្នើឲ្យមានកែសម្រួល ឬធ្វើការបកស្រាយនូវខ្លឹមសារមួយមិនច្បាស់លាស់ នៅស្របពេលដែលសេចក្តីស្នើច្បាប់ទាំងពីរនេះ មានចំណុចអវិជ្ជមានមួយចំនួន ដែលភាគីពាក់ព័ន្ធបានស្នើឲ្យអ្នកតំណាងរាស្ត្រធ្វើការកែសម្រួល ដើម្បីធានាការរៀបចំសមាសភាព ការបំពេញការងាររបស់ គ.ជ.ប និងការរៀបចំបញ្ជីបោះឆ្នោត និងការបោះឆ្នោតបានល្អប្រសើរជាង រយៈពេលកន្លងមក។

ចំណែកឯសម័យប្រជុំសាមញ្ញសាធារណៈលើកទី៤វិញឃើញថា ការពិភាក្សា និងអនុម័តសេចក្តីព្រាង/ស្នើច្បាប់ ចំនួន០៥ច្បាប់ រួមមានសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ សេចក្តីព្រាងច្បាប់ស្តីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់ សេចក្តីស្នើច្បាប់ស្តីពី ភតិកិច្ចសន្យាពិសេស និងវិសោធនកម្មច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ, ច្បាប់ស្តីពី វិសោធនកម្មមាត្រា ៣,៤,៥,២៦,២៧,២៨,៤២,៧៤ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែល

ត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីអគ្គិសនីនៃ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៧ និងការជជែកដេញដោលពីគណបក្សសម្លេងភាគច្រើន និងគណបក្សសម្លេងភាគតិចក្នុងរដ្ឋសភា។

ដោយឡែក មានសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអនុម័តមានសម្លេងតែគណបក្សមួយគត់ គឺគណបក្សប្រជាជនកម្ពុជា ដោយមិនមានសម្លេងចូលរួមអនុម័តពីគណបក្សសង្គ្រោះជាតិឡើយ ដោយអ្នកតំណាងរាស្ត្រគណបក្សនេះបានលើកឡើងអំពីចំណុចខ្វះខាត និងត្រូវការពេលវេលាបន្ថែមក្នុងការអនុម័តច្បាប់ទាំងពីរនេះ។ ការបញ្ចេញមតិនៃការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ មានការចូលរួមពីអ្នកតំណាងរាស្ត្រមកពីគណបក្សទាំងពីរជជែកដេញដោល ប៉ុន្តែតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ មិនចូលរួមក្នុងការអនុម័តលើច្បាប់នេះឡើយ ដោយលើកហេតុផលថា ច្បាប់នេះមានភាពមិនប្រក្រតីនូវការចំណាយមួយចំនួន និងទាមទាររកឯកសារបន្ថែម។ ដោយឡែកការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តំណាង រាស្ត្រពីគណបក្សសង្គ្រោះជាតិបានធ្វើពហិការមិនចូលរួមក្នុងការអនុម័តលើច្បាប់នេះទេ ដោយបញ្ជាក់ថា ច្បាប់នេះត្រូវការពេលវេលាពិគ្រោះយោបល់បន្ថែម។ ចំពោះខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាផ្តោតលើការពន្យល់នូវចំណុចវិជ្ជមាននៃច្បាប់នេះដល់សារធារណជន ដោយសារតែច្បាប់នេះរងការរិះគន់ពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិថា មានការរឹតត្បឹតសិទ្ធិសេរីរបស់អង្គការសង្គមស៊ីវិល។

### ១.១.៣ គុណភាពនៃការពិភាក្សា និងអនុម័តច្បាប់

ឆមាសដើមឆ្នាំទី២ សង្កេតនេះ ខុមហ្វ្រែលសង្កេតឃើញថា មានសេចក្តីស្នើច្បាប់ ចំនួន០២ រួមមាន សេចក្តីស្នើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវបានរដ្ឋសភាយកមកអនុម័តតែម្តង ដោយមិនមានការពិភាក្សា ឬក៏ជជែកសួរដេញដោលនោះទេ ចំណែកឯរបៀបវារៈចំនួន០៣ រួមមានការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣ សេចក្តីស្នើច្បាប់ស្តីពីភតិកិច្ចសន្យា និងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល រដ្ឋសភាបានប្រើរយៈពេលត្រឹមតែ ១កិច្ចប្រជុំប៉ុណ្ណោះ (១ព្រឹក) ក្នុងការពិភាក្សា និងអនុម័ត។

តាមការអង្កេត សម័យប្រជុំសភាជាវិសាមញ្ញទី៣ និងសាមញ្ញលើទី៤ ឃើញថា រដ្ឋសភាហាក់ដូចជាធ្វើការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់មួយចំនួន មានលក្ខណៈប្រញាប់ប្រញាល់ជាងការពិភាក្សា និងអនុម័តក្នុងសម័យប្រជុំអនុម័តច្បាប់លើកមុនៗ។ ជាក់ស្តែងសម័យប្រជុំសភាជាវិសាមញ្ញលើកទី៣ មានសេចក្តីព្រាងច្បាប់ចំនួន០២ រួមមានសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានរដ្ឋសភា ធ្វើការពិភាក្សា និងអនុម័ត ដោយប្រើរយៈពេលត្រឹមតែ១កិច្ចប្រជុំប៉ុណ្ណោះ (ប្រើថេរវេលា៦ម៉ោងកន្លះ)។ ក្នុងកិច្ចប្រជុំវិសាមញ្ញនេះ មានតែអ្នកតំណាងរាស្ត្រម្នាក់ប៉ុណ្ណោះឡើងបញ្ចេញមតិលើខ្លឹមសារច្បាប់ ប៉ុន្តែពុំមានការជជែកពិភាក្សា ក្រៅតែពីសរសើរក្រុមការងារតាក់តែងច្បាប់ និងស្នើមិនឲ្យមានការពិភាក្សា ដោយអះអាងថា សេចក្តីស្នើច្បាប់ទាំងនេះត្រូវបានពិនិត្យ និងពិគ្រោះយោបល់គ្នា រវាងក្រុមការងារតាក់តែងច្បាប់នៃគណបក្សទាំងពីររួចអស់ហើយ។

រីឯសម័យប្រជុំសភាសាមញ្ញសាធារណៈលើកទី៤វិញ ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ចំនួន០២ រួមមាន សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងសេចក្តីព្រាងច្បាប់ស្តីពី សមាគម និង

អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអនុម័តដោយសម្លេងគាំទ្រ តែគណបក្សមួយប៉ុណ្ណោះ។ តួយ៉ាង ការពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវបានចូលរួមដោយគណបក្សសង្គ្រោះជាតិតែគណបក្សនេះមិនចូលរួមក្នុងការលើកដៃអនុម័ត ដោយហេតុផលថា នៅមានភាពមិនប្រក្រតីក្នុងការទូទាត់ថវិកាចំណាយ។ ចំណែកឯការពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានតែគណបក្សប្រជាជនប៉ុណ្ណោះចូលរួមក្នុងការអនុម័ត និងពិភាក្សា ដោយគណបក្សសង្គ្រោះជាតិ ធ្វើពហិការមិនចូលរួមក្នុងការអនុម័ត និងពិភាក្សាលើសេចក្តីព្រាងច្បាប់នេះទេ ដោយតែសារច្បាប់នេះមានចំណុចជាច្រើនត្រូវផែក និងស្នើឲ្យរយៈពេលក្នុងពិភាក្សាបន្ថែមទៀត។ យ៉ាងណាក៏ដោយច្បាប់ទាំងពីរនេះត្រូវបាន រដ្ឋសភាធ្វើការអនុម័តជាស្ថាពរ បើទោះបីជាមិនមានវត្តមានរបស់គណបក្សសង្គ្រោះជាតិក្នុងការអនុ ម័តក៏ដោយ។ ជុំវិញនូវការអនុម័តច្បាប់នេះ រដ្ឋសភាទទួលនូវការរិះគន់ពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ថាមិនទាន់ដល់ពេលក្នុងការអនុម័តច្បាប់នេះ។

### ១.២ ដំណើរការនៃការប្រជុំ/សួរដេញដោលរបស់គណៈកម្មការជំនាញនៃរដ្ឋសភា

ក្នុងអំឡុងពេល១ ឆមាសដើម ឆ្នាំ២០១៥ គណៈកម្មការជំនាញនៃរដ្ឋសភាបានធ្វើសកម្មភាពសកម្មច្រើនជាងរយៈពេលដូចគ្នាក្នុងដើមឆ្នាំ២០១៤។ គណៈកម្មការជំនាញៗនៃរដ្ឋសភា បានធ្វើការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ និងសកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬ/និងប្រជាពលរដ្ឋ ដើម្បីពិនិត្យ និងស្វែងយល់ពីបញ្ហា និងកង្វល់នានា និងព្រមទាំងចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ ពិសេសបញ្ហាទំនាស់ដីធ្លី។ ការសង្កេតឃើញថា មានគណៈកម្មការជំនាញទាំង១០នៃរដ្ឋសភាបានធ្វើសកម្មភាពរបស់ខ្លួន ចំនួន៤៥លើក ដែលក្នុងនោះ គណៈកម្មការទី១ មានសកម្មភាពចំនួន៥លើក គណៈកម្មការទី២ មានសកម្មភាពចំនួន៣លើក គណៈកម្មការទី៣ មានសកម្មភាពចំនួន៨លើក គណៈកម្មការទី៤ មានសកម្មភាពចំនួន៥លើក គណៈកម្មការទី៥ មានសកម្មភាពចំនួន៨លើក គណៈកម្មការទី៦ មានសកម្មភាពចំនួន៤លើក គណៈកម្មការទី៧ មានសកម្មភាពចំនួន៣លើក គណៈកម្មការទី៨ មានសកម្មភាពចំនួន៤លើក គណៈកម្មការទី៩ មានសកម្មភាពចំនួន២លើក និងគណៈកម្មការទី១០ មានសកម្មភាពចំនួន៣លើក។

គណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបានធ្វើសកម្មភាពគួរឲ្យកត់សម្គាល់ ខុសប្លែកពីរយៈពេលកន្លងមក។ ការសង្កេតឃើញថា គណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិមានសកម្មភាពប្រហាក់ប្រហែលគ្នា។ ក្នុងរយៈពេល០៦ខែ គណៈកម្មការជំនាញដឹកនាំដោយ គណបក្សសង្គ្រោះជាតិមានសកម្មភាពចំនួន២៥លើក រីឯគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមានសកម្មភាពចំនួន ២០លើក។

ក្នុងរយៈពេលនេះដែរ ការសង្កេតឃើញថា មានរដ្ឋមន្ត្រីចំនួន៨រូប រួមមានដូចជា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានហៅមកបំភ្លឺដោយផ្ទាល់មាត់ជាមួយគណៈកម្មការជំនាញរដ្ឋសភា។ ជាមួយគ្នានេះក៏មានការកោះអញ្ជើញតំណាងអង្គការសង្គមស៊ីវិលចូលបំភ្លឺបញ្ហាមួយចំនួនជាមួយគណៈកម្មការជំនាញផងដែរ។

ជាក់ស្តែងគណៈកម្មការជំនាញទី៧នៃរដ្ឋសភា ដឹកនាំដោយអ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ មកពីគណបក្សសង្គ្រោះជាតិបានអញ្ជើញរដ្ឋមន្ត្រីចំនួន៤រូប មកបំភ្លឺផ្ទាល់មាត់នៅក្នុងរដ្ឋសភារួមមាន លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ លោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោក មិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងលោកស្រី ភឿង សកុណា រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈដើម្បីបំភ្លឺជុំវិញរឿងមរណីយដ្ឋានភ្នំបូកគោ។

បន្ថែមលើនេះ គណៈកម្មការជំនាញទី១នៃរដ្ឋសភា ដឹកនាំដោយលោក អេង ឆៃអ៊ាង បានអញ្ជើញលោក សួន ប៊ុនស័ក្តិ តំណាងអង្គការសង្គមស៊ីវិលដែលធ្វើការលើរឿងដីធ្លី ដើម្បីពិភាក្សាការងារលើរឿងជម្លោះដីធ្លីនៅកម្ពុជា និងកោះអញ្ជើញលោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បំភ្លឺពីករណីទំនាស់ដីធ្លីនៅស្រុកបទុមសាគរ និងស្រុកគិរីសាគរខេត្តកោះកុង។

លើសពីនេះ គណៈកម្មការជំនាញទី៣នៃរដ្ឋសភា ដឹកនាំដោយលោក ប៉ុល ហំម បានអញ្ជើញ លោក ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ មកបំភ្លឺពីកិច្ចដំណើរការការងារ និងបញ្ហាប្រឈមផ្សេងៗរបស់ក្រសួងផែនការ និងជួបពិភាក្សាការងារជាមួយលោក អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកសាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីស្វែងយល់លទ្ធផលការងារនៃក្រសួងសាមី។ គណៈកម្មការទី៣ ដដែលក៏បានជួបពិភាក្សាការងារជាមួយក្រុមអង្គការសង្គមស៊ីវិល រួមមាន វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum)។ រីឯគណៈកម្មការទី០៨ លោកស្រី កែ សុវណ្ណរតន៍ បានជួបពិភាក្សាជាមួយ ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រី ក្រសួងសុខាភិបាល លើសេចក្តីព្រាងច្បាប់ស្តីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់។

ដោយឡែក គណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានធ្វើសកម្មភាពមួយចំនួនដូចជា គណៈកម្មការជំនាញទី២នៃរដ្ឋសភា ដឹកនាំដោយ លោក ជាម យៀប បានជួបពិភាក្សាការងារជាមួយ លោក មុំ គង់ នាយកប្រតិបត្តិអង្គការសម្ព័ន្ធដើម្បីសុខភាពកម្ពុជា ក្នុងគោលបំណងស្វែងយល់ពីសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ នៅវិមានរដ្ឋសភា។ គណៈកម្មការទី៥នៃរដ្ឋសភា ដឹកនាំដោយលោក ឈាង វុន បានចុះទៅសាលាស្រុកថ្មគោលខេត្តបាត់ដំបង ដើម្បីចូលរួមពិធីផ្សព្វផ្សាយសភាពការណ៍នយោបាយក្រោយថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ និងធ្វើបទបង្ហាញភូមិសាស្ត្រនយោបាយ ដើម្បីការសម្រេចត្រឹមត្រូវ និងវិស័យការទូតសភានៅសកលវិទ្យាល័យបាត់ដំបង។ គណៈកម្មការទី៤នៃរដ្ឋសភា ដឹកនាំដោយលោក ហ៊ុន ណេង បានដឹកនាំសមាជិក សមាជិកា ចុះបំពេញបេសកកម្មសិក្សាស្វែងយល់ការងារពាក់ព័ន្ធនឹងភារកិច្ចគណៈកម្មការនៅខេត្តកណ្តាល និងខេត្តតាកែវ។ គណៈកម្មការទី៦នៃរដ្ឋសភា ដឹកនាំដោយលោក ប៉ែន បញ្ញា បានចុះបំពេញបេសកកម្មនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដើម្បីសិក្សាស្វែងយល់ពីការអនុវត្តន៍ច្បាប់ និងការប្រព្រឹត្តិទៅនៃប្រពន្ធ័តុលាការក្នុងខេត្តទាំងពីរនេះ។ គណៈកម្មការទី៩នៃរដ្ឋសភា ដឹកនាំដោយលោកស្រី និន សាផុន បានចុះបំពេញបេសកម្មនៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ស្វែងយល់ពីសកម្មភាពការងារ ទិសទៅអនុវត្តបន្ត និងចុះពិនិត្យសិមិទ្ធផលនានាក្នុងខេត្តទាំងពីរ។

ក្នុងអំឡុងពេលនេះដែរ សង្កេតឃើញមានកិច្ចអន្តរាគមន៍ពីគណៈកម្មការជំនាញនៃរដ្ឋសភា មានសកម្មភាពជាងឆ្នាំមុន ជាក់ស្តែង គណៈកម្មការទី១នៃរដ្ឋសភា បានចុះធ្វើសិក្សាស្រាវជ្រាវលើបណ្តឹងមានចំនួន០៤ករណី។ ជាក់ស្តែងថ្ងៃទី២០ មករា ឆ្នាំ២០១៥ គណៈកម្មការជំនាញទី១នៃរដ្ឋសភា ដឹកនាំដោយលោក អេង ឆៃអ៊ាង ចុះបេកសកម្មដើម្បីពិនិត្យ អង្កេត ស្រាវជ្រាវពីករណីទំនាស់ដីធ្លីក្នុងខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ តាមពាក្យបណ្តឹងប្រជាពលរដ្ឋ ដាក់ជូនគណៈកម្មការជំនាញរដ្ឋសភា ដោយជួបជាមួយប្រជាពលរដ្ឋរងគ្រោះទាំងពីរខេត្ត និងក្រុមហ៊ុនវិនិយោគចំការកៅស៊ូ Co.LTD ក្រុមហ៊ុនយូប៊ីអ៊ី ឌីវេឡុបមេន ក្រុមហ៊ុនដាយណាម ក្រុមហ៊ុនកាសូទឹម និងក្រុមហ៊ុនដូងទៀងក្រចេះ រ៉ាប់បើរឌីវេឡុបមេន លីមីធីត។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ គណៈកម្មការទី១ ដដែល បានធ្វើការសម្របសម្រួលដោះស្រាយករណីបណ្តឹងវិវាទរបស់ប្រជាពលរដ្ឋនៅភូមិឡពាងដោយចុះផ្ទាល់ទៅទីតាំងចំនួន៧លើក និងជួបនៅភ្នំពេញចំនួន៥លើក និងចុះទៅសួរពីការសំរេចចិត្តរបស់ប្រជាជនមានទំនាស់ដីនៅភូមិឡពាង។ លើលពីនេះ នៅថ្ងៃទី២២-២៤ ខែមីនា ឆ្នាំ២០១៥ គណៈកម្មការទី១នៃរដ្ឋសភា បន្តបេសកកម្មចុះអង្កេតលើករណីបញ្ហាជម្លោះដីធ្លី ចំនួន១៧ករណី ក្នុងស្រុកចំនួន៣នៃខេត្តព្រះសីហនុ គឺស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងក្រុងព្រះសីហនុ ដោយបានជួបប្រជាពលរដ្ឋនរស់នៅក្នុងតំបន់ទំនាស់ និងបានពិនិត្យទីតាំងដីទំនាស់ និងជួបពិភាក្សាជាមួយលោក

ឈិត សុខុន អភិបាលខេត្តព្រះសីហនុ រួមទាំងអាជ្ញាធរថ្នាក់ស្រុក/ខណ្ឌ និងសង្កាត់/ឃុំ ដើម្បីរកដំណោះស្រាយជូនប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទំនាស់។ ការអន្តរាគមន៍នេះ សង្កេតឃើញមានទទួលបានលទ្ធផល ដោយមានការឆ្លើយពីអាជ្ញាធរខេត្ត ដោយបានដោះស្រាយជូនប្រជាពលរដ្ឋទំនាស់ នៅស្ពានឆេះអូរត្រេះ ធ្វើការចាប់ឆ្នោតដីសម្បទានសង្គមកិច្ច ចំពោះករណីប្រជាពលរដ្ឋរងទំនាស់ដទៃ អាជ្ញាធរនឹងធ្វើការដោះស្រាយជូនបន្តទៀត។ បន្ថែមលើនេះ បន្ទាប់ពីបានទទួលពាក្យបណ្តឹងពីប្រជាជននៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ គណៈកម្មការទី១នៃរដ្ឋសភា បានចុះមកភ្លាម ចុះជួបប្រជាពលរដ្ឋរងវិវាទដីធ្លី ករណីទំនាស់ដីធ្លី រវាងប្រជាពលរដ្ឋភូមិកំពង់អុស ជាមួយក្រុមហ៊ុនឧកញ៉ា អេង ឌីប៉ូ អភិវឌ្ឍន៍ នៅឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល ដោយមានបណ្តឹងមកគណៈកម្មការទី១នៃរដ្ឋសភា។ គណៈកម្មការ បានធ្វើការអង្កេត និងប្រមូលព័ត៌មានទាំងសងខាងដើម្បីធ្វើការសិក្សា ស្រាវជ្រាវ សម្របសម្រួល និងសំណូមពរជម្រុញអោយស្ថាប័នពាក់ព័ន្ធទាំងអស់ចូលរួមពន្លឿនការដោះស្រាយជូនប្រជាពលរដ្ឋ និងក្រុមហ៊ុនឲ្យបានឆាប់។

## II. សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ

ព័ត៌មានអំពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ អ្នកសង្កេតការណ៍ខុមហ្វ្រែល បានប្រមូលពីការិយាល័យតំណាងរាស្ត្រតាមបណ្តារាជធានី ខេត្ត ពីស្នាក់ការគណបក្សនយោបាយប្រចាំរាជធានី ខេត្ត ពីប្រព័ន្ធផ្សព្វផ្សាយនានា និងពីជំនួយការអ្នកតំណាងរាស្ត្រផ្ទាល់ទៅតាមលទ្ធភាព និងមធ្យោបាយដែលអ្នកសង្កេតការណ៍អាចធ្វើបាន។ ដូច្នេះព័ត៌មានដែលយើងខ្ញុំទទួលបានពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រទាំងពីរគណបក្សនេះ អាចតិចជាងចំនួនចុះជាក់ស្តែង ដោយហេតុថា ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រភាគច្រើន គឺមិនបានផ្តល់ព័ត៌មានជាក់លាក់ទៅឱ្យមន្ត្រីការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលនោះឡើយ។ ទន្ទឹមគ្នានេះអ្នកសង្កេតការណ៍ខុមហ្វ្រែលក៏ជួបការលំបាកក្នុងការប្រមូលព័ត៌មានពីអ្នកតំណាងរាស្ត្រមួយចំនួន ជាពិសេសរបាយការណ៍សកម្មភាពរបស់អ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។

### ២.១ សកម្មភាពរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា

នៅក្នុងអំឡុងពេលពីខែមករា ដល់ខែមិថុនា តាមព័ត៌មានដែលខុមហ្វ្រែលទទួលបានមានអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា ចំនួន៣៨រូប ស្មើនឹង ៥៥,៨៨% នៃចំនួនអ្នកតំណាងរាស្ត្រសរុបដែលមានចំនួន៦៨រូប បានចុះមូលដ្ឋានសរុប៨៥លើក។

**<u>តារាងទី១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា</u>**

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ៨៥លើករបស់តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា** | ៣៨ រូប |
|---|---|
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ភោធសមិទ្ធផលនានា | ៤៨ លើក |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ០៧ លើក |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ២៧ លើក |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ០២ លើក |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ០១ លើក |
| **សរុបគោលបំណងតាមគណបក្ស** | **៨៥** លើក |

តារាងទី១ខាងលើនេះ បង្ហាញពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រដែលភាគច្រើន ការចុះមូលដ្ឋានផ្តោតទៅលើគោលបំណងជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន ៤៨លើក (ស្មើនឹង៥៦,៤៧%នៃការចុះមូលដ្ឋានសរុប)។ ការចុះមូលដ្ឋានក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនមានចំនួន ២៧លើក (ស្មើនឹង៣១,៧៦%នៃការចុះមូលដ្ឋានសរុប) ក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមានចំនួន ០៧លើក (ស្មើនឹង៨,២៤%នៃចំនួនចុះមូលដ្ឋានសរុប) ក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានចំនួន ០២លើក (ស្មើនឹង២,៣៥%នៃការចុះមូលដ្ឋានសរុប) និងក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋមានចំនួន១ លើក (ស្មើនឹង១,០៧%នៃការចុះមូលដ្ឋានសរុប)។

គួរបញ្ជាក់ដែរថា តារាងខាងលើ ខុមហ្វ្រែលសង្កេតឃើញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ការចុះមូលដ្ឋានគឺភាគច្រើនផ្តោតតែទៅលើការចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ ដោយមិនសូវមានសកម្មភាពអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋទេ។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៣៨រូប ចុះបានសរុប៨៥លើក) ខាងក្រោមនេះគឺជាករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនេះ៖**

អ្នកតំណាងរាស្ត្រ **ហ៊ុន ម៉ានី** មណ្ឌលកំពង់ស្ពឺ អ្នកតំណាងរាស្ត្រ**ប៉ែន បញ្ញា** មណ្ឌលព្រៃវែង និងអ្នកតំណាងរាស្ត្រ **ជាម យៀប** មណ្ឌលព្រៃវែង ចុះមូលដ្ឋានច្រើនជាងគេ ក្នុងចំណោមអ្នកតំណាងរាស្ត្រនៃគណបក្សខ្លួន។ ជាក់ស្តែងកាលពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៥ ឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រ មណ្ឌលកំពង់ស្ពឺ ចូលរួមក្នុងកម្មវិធីកាត់ខណ្ឌសីមាវត្តព្រៃឈៀង ឃុំឫស្សីសាញ់ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។ បន្ថែមលើនេះ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រ មណ្ឌលកំពង់ស្ពឺ បានចុះបំពាក់ឧបករណ៍ជំនួយត្រចៀកជូនប្រជាពលរដ្ឋចាស់ជរា និងកុមារចំនួន១៤៩៤នាក់។ ចំណែកឯកឧត្តម **ប៉ែន បញ្ញា** អ្នកតំណាងរាស្ត្រ មណ្ឌលព្រៃវែង កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋរងគ្រោះអគ្គិភ័យឆាបឆេះផ្សារកអណ្តើក ស្ថិតនៅក្នុងភូមិប្រសាទ ឃុំប្រសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និងនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ឯកឧត្តមបានជួបប្រជុំជាមួយមន្ត្រីគណបក្សស្រុកកំពង់ត្របែកនៅទីស្នាក់ការគណបក្សប្រចាំស្រុកកំពង់ត្របែក។ រីឯ ឯកឧត្តម **ជាម យៀប** អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង ជួបជុំជាមួយសកម្មជនគណបក្ស ដើម្បីប្រជុំបូកសរុបការងារប្រចាំខែមីនា នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្ថិតក្នុង ឃុំកំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ និងនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៥ ឯកឧត្តមបានចុះជួបប្រជុំជាមួយសមាជិកគណបក្ស ប្រជាពលរដ្ឋប្រមាណ ៦១២នាក់ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្ថិតនៅក្នុងឃុំ កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ក្នុងគោលបំណងផ្សព្វផ្សាយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

## ២.២ សកម្មភាពរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ

នៅក្នុងអំឡុងពេលពីខែមករា ដល់ដើមខែមិថុនា នៃនីតិកាលទី៥នេះ តាមព័ត៌មានដែលខុមហ្វ្រែលទទួលបានពីបណ្តាញរបស់ខ្លួន គណបក្ស ការិយាល័យតំណាងរាស្ត្រ និងពីប្រព័ន្ធផ្សព្វផ្សាយនានា មានអ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន ៣២រូប ស្មើនឹង៥៨,២០%នៃចំនួនអ្នកតំណាងរាស្ត្រសរុបដែលមានចំនួន៥៥រូប បានចុះមូលដ្ឋាន/ធ្វើសកម្មភាពសរុប ៥២៧លើក។

**តារាងទី២៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ**

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ៥២៧លើករបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ** | ៣២ រូប |
|---|---|
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ | ៣៣១ លើក |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ៧៧ លើក |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៨៦ លើក |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ២២ លើក |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ១១ លើក |
| **សរុបគោលបំណងតាមគណបក្ស** | **៥២៧** លើក |

តារាងទី២នេះ បង្ហាញពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ភាគច្រើនផ្តោតទៅលើគោលបំណងជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយមានចំនួន ៣៣១លើក (ស្មើនឹង ៦២,៨១% នៃការចុះមូលដ្ឋានរបស់បក្សខ្លួនសរុប)។ ការចុះមូលដ្ឋានក្នុងគោលបំណងពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមានចំនួន ៧៧លើក (ស្មើនឹង ១៤,៦១%នៃការចុះមូលដ្ឋានរបស់បក្សខ្លួនសរុប) ក្នុងគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំមានចំនួន ៨៦លើក (ស្មើនឹង ១៦,៣២%នៃចំនួនចុះមូលដ្ឋានសរុប) ក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានចំនួន ២២លើក (ស្មើនឹង៤,១៧%នៃការចុះមូលដ្ឋានសរុប) និងក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋមានចំនួន ១១លើក (ស្មើនឹង ២,០៩%នៃការចុះមូលដ្ឋានសរុប)។

គួរបញ្ជាក់ដែរថា តារាងខាងលើ ខុមហ្វ្រែលសង្កេតឃើញថាតំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិការចុះមូលដ្ឋានគឺភាគច្រើនផ្តោតលើគោលបំណងជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស។ ជាមួយគ្នានេះតំណាងរាស្ត្រក៏បានធ្វើសកម្មភាពក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋផងដែរ។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ( ៣២រូប ចុះបានសរុប ៥២៧លើក) ខាងក្រោមនេះ គឺជាករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនេះ៖**

អ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៍** មណ្ឌលសៀមរាប អ្នកតំណាងរាស្ត្រ **ចាន់ ចេង** មណ្ឌលកណ្តាល និងអ្នកតំណាងរាស្ត្រ **កង គឹមហាក់** មណ្ឌលព្រៃវែង បានចុះមូលដ្ឋានច្រើនជាងគេក្នុងចំណោមតំណាងរាស្ត្រគណបក្សខ្លួន។ ជាក់ស្តែងកាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៥ លោកជំទាវ **កែ សុវណ្ណរតន៍** តំណាងរាស្ត្រមណ្ឌលសៀមរាប បានចុះទៅសួរសុខទុក្ខ និងសំណេះសំណាលជាមួយប្រជាពលរដ្ឋរងគ្រោះរឿងដីធ្លីចំនួន ៣០គ្រួសារ ដែលមិនទាន់បានទទួលសំណងពីការអភិវឌ្ឍន៍ទំនប់ម្កាក់របស់ក្រុមហ៊ុនចិន នៅភូមិដុបត្នោត ឃុំពង្រលើ ស្រុកជីក្រែង ខេត្តសៀមរាប និងនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ លោកជំទាវបានចុះទៅសួរសុខទុក្ខ និងសំណេះសំណាលជាមួយប្រជាពលរដ្ឋរងគ្រោះដោយសារការឆ្លងជំងឺអេដស៍នៅភូមិរកា ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៥ ឯកឧត្តម **ចាន់ ចេង** អ្នកតំណាងរាស្ត្រមណ្ឌលកណ្តាល បានចុះពង្រឹងរចនាសម្ព័ន្ធគណបក្ស ដែលបានរៀបចំឡើងនៅទីស្នាក់ការគណបក្សសង្គ្រោះជាតិ ស្រុកខ្សាច់កណ្តាល និងស្រុក

មុខកំពូល ដោយមានសកម្មជនមូលដ្ឋានរបស់ខ្លួនចូលរួមចំនួន ១៣២រូប និងកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៥ ឯកឧត្តមបានចុះប្រជុំបូកសរុបការងារផ្ទៃក្នុងគណបក្សនៅទីស្នាក់ការគណបក្សស្រុកកោះធំ ខេត្តកណ្ដាល ដោយមានសមាជិកចូលរួមចំនួន៣៨រូប។ ចំណែកអ្នកតំណាងរាស្ត្រ **កង គឹមហាក់** មណ្ឌលកំពង់ចាម នារសៀលថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ឯកឧត្តមរួមនិងសមាជិករបស់គណៈកម្មការទី៣ បានជួបប្រជុំ សួរសុខទុក្ខ និងធ្វើការសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋនៅភូមិអន្លង់ស្វាយ ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដែលកំពុងតែមានក្ដីព្រួយបារម្ភចំពោះគម្រោងការសាងសង់ទំនប់វារីអគ្គិសនីដនសាហុង របស់ប្រទេសឡាវ និងកាលពីថ្ងៃ២៦ ខែមេសា ឆ្នាំ២០១៥ ឯកឧត្តមបានចុះបូកសរុបលទ្ធផលការងារ និងរៀបចំរចនាសម្ព័ន្ធថ្នាក់មូលដ្ឋាន និងផែនការសកម្មភាពជាមួយថ្នាក់ដឹកនាំថ្នាក់មូលដ្ឋានរបស់គណបក្សនៅទីស្នាក់ការគណបក្សសង្គ្រោះជាតិ ស្ថិតនៅភូមិរកាទ្វារ ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

### ២.៣ សកម្មភាពរបស់តំណាងពីគណបក្សប្រជាជនកម្ពុជាធៀបនឹងសកម្មភាពតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ

ខាងក្រោមនេះគឺជាការប្រៀបធៀបអំពីចំនួនជារួម និងចំនួនទៅតាមគោលបំណងនៃការចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា និងតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ។

<u>ក្រាហ្វិកទី១៖ ចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាធៀបនឹងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ</u>




បើប្រៀបធៀបនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងតំណាងរាស្ត្ររបស់គណបក្សសង្គ្រោះជាតិ នៅក្នុងចន្លោះពេលនេះឃើញថា ចំនួនចុះមូលដ្ឋាន/ធ្វើសកម្មភាពរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមានចុះធ្វើសកម្មភាពមូលដ្ឋានច្រើនជាងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។

តាមទិន្នន័យដែលខុមហ្វ្រែលទទួលបាន អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានសរុប ៨៥ លើក ហើយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពនៅមូលដ្ឋានសរុប ៥២៧លើក។

<u>**តារាងទី៣៖ ការប្រៀបធៀបចំនួននៃការចុះមូលដ្ឋានតាមគោលបំណងរវាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា និងតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ**</u>

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ៦១២ លើករបស់តំណាងរាស្ត្រនៃគណបក្សទាំងពីរ** | ៣៨ រូប | ៣២ រូប | **សរុបគោលបំណង** |
|---|---|---|---|
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ៤៨ (៥៦.៤៧%) | ៣៣១ (៦២.៨១%) | **៣៧៩** (៦១.៩៣%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ០៧ (៨.២៤%) | ៧៧ (១៤.៦១%) | **៨៤** (១៣.៧៣%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ២៧ (៣១.៧៦%) | ៨៦ (១៦.៣១%) | **១១៣** (១៨.៤៦%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ០២ (២.៣៥%) | ២២ (៤.១៧%) | **២៤** (៣.៩២%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ០១ (១.១៨%) | ១១ (២.០៩%) | **១២** (១.៩៦%) |
| **សរុបគោលបំណងតាមគណបក្ស** | **៨៥** (១០០%) | **៥២៧** (១០០%) | **៦១២** (១០០%) |

<u>**ក្រាហ្វិកទី២៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភា**</u>

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបទៅនឹងភាគរយនៃអាសនៈរដ្ឋសភាតាមគណបក្សក្នុងអំឡុងរយៈពេលឆមាសនេះ បានបង្ហាញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលមានអាសនៈ៥៥% នៅក្នុងរដ្ឋសភា បានចុះមូលដ្ឋាន ១៣,៨៩% នៃចំនួនចុះមូលដ្ឋានសរុប។ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលមានអាសនៈ៤៥% នៅក្នុងរដ្ឋសភា បានចុះមូលដ្ឋានបាន ៨៦,១១% នៃការធ្វើសកម្មភាពសរុប។



### ២.៤ ដំណើរការមិនប្រក្រតីនៃការិយាល័យតំណាងរាស្ត្រ

ការិយាល័យតំណាងរាស្ត្រ ជាទីកន្លែងធ្វើការងាររបស់អ្នកតំណាងរាស្ត្រ នៅពេលដែលតំណាងរាស្ត្រចុះមូលដ្ឋាននោះ និងជាកន្លែងផ្សារភ្ជាប់ទំនាក់ទំនងរវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ លើសពីនេះ ការិយាល័យតំណាងរាស្ត្រក៏ជាទីកន្លែងមួយដែលសម្រាប់បម្រើដល់ផលប្រយោជន៍ប្រជាពលរដ្ឋដោយមិនប្រកាន់ពីគណបក្សនយោបាយ និងជាកន្លែងមួយសម្រាប់ទទួលពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋ ដើម្បីផ្ញើជូនទៅអ្នកតំណាងរាស្ត្រ ដែលជាអ្នកតំណាងរបស់ខ្លួន ធ្វើការដោះស្រាយតាមមធ្យោបាយផ្សេងៗ។

អ្នកសង្កេតការណ៍ខុមហ្វ្រែលប្រចាំក្នុងរាជធានី-ខេត្តទាំងអស់បានសង្កេតឃើញថា ដំណើរការនៃការិយាល័យតំណាងរាស្ត្រនៅតាមបណ្ដាខេត្តមួយចំនួនហាក់មានដំណើរការប្រសើរជាងមុន ដោយមានការបើកដំណើរការបំពេញតួនាទីការងារ ប៉ុន្តែនៅមានការិយាល័យខ្លះមានដំណើរមិនប្រក្រតី ព្រោះមិនបានបំពេញតួនាទីការងាររបស់ខ្លួនឡើយ ដោយបានបិទទ្វារមិនដំណើរការ ឬដំណើរការមិនពេញលេញ។

ការឃ្លាំមើលឃើញថា ក្នុងចំណោមរាជធានី/ខេត្ត ដែលមានការិយាល័យតំណាងរាស្ត្រ បានបើកដំណើរការ និងបំពេញតួនាទីខ្លួនក្នុងនោះរួមមានខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកណ្ដាល ខេត្តប៉ៃលិន ខេត្តកោះកុង ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ។ ប៉ុន្តែមានសេចក្ដីរាយការណ៍ពីមន្ត្រីបម្រើការនៅតាមការិយាល័យតំណាងរាស្ត្រទាំងនោះថា ខ្លួនមិនបានទទួល ព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រពេញលេញនោះទេ ដោយសារតែអ្នកតំណាងរាស្ត្រភាគច្រើនមិនបានផ្ដល់ព័ត៌មាននៅពេលដែលខ្លួនចុះបេសកកម្ម។ ដោយឡែកការិយាល័យតំណាងរាស្ត្រប្រចាំខេត្តបន្ទាយមានជ័យវិញ មានសេចក្ដីរាយការណ៍ថា មិនទាន់មានបុគ្គលិកបម្រើការគ្រប់គ្រាន់នោះទេ ពោលគឺមានមន្ត្រីបម្រើការតែម្នាក់ប៉ុណ្ណោះ ខណៈដែលបានស្នើសុំបន្ថែម ប៉ុន្តែមិនទាន់ឃើញសេចក្ដីសម្រេច។

ដោយឡែកការិយាល័យតំណាងរាស្ត្រក្នុងខេត្តកែបមិនទាន់បានបើកដំណើរការ និងបំពេញតួនាទីការងារខ្លួនទេ ដោយមិនទាន់មានមន្ត្រីប្រចាំការ ដោយសារតែការិយាល័យទើបនឹងសាកសង់ហើយ រីឯការិយាល័យតំណាងរាស្ត្រក្នុងខេត្តមណ្ឌលគីរីមិនទាន់សាងសង់រួចរាល់នោះទេ។ ខណៈដែលខេត្តឧត្ដរមានជ័យ និងខេត្តពោធិ៍សាត់ មិនទាន់មានការិយាល័យតំណាងរាស្ត្រនៅឡើង។

## III. ដំណើរការអគ្គលេខាធិការដ្ឋានរដ្ឋសភា និងកិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា

### ៣.១ ការអនុវត្តន៍ចំពោះលិខិតចូលរបស់អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា ជាសេនាធិការផ្ទាល់របស់រដ្ឋសភា ទទួលបន្ទុកខាងការរៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភា និងរបស់គណៈកម្មការនានា និងទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាល និងផ្ដល់សេវាទ្រទ្រង់លើការងារទូទៅនានាជូនរដ្ឋសភា និងគណៈកម្មការទាំងអស់ ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅរដ្ឋសភា[2]។

រាល់លិខិតដែលដាក់ជូនឲ្យរដ្ឋសភាត្រូវឆ្លងតាមរដ្ឋបាលរដ្ឋសភា បន្ទាប់មករដ្ឋបាលរដ្ឋសភាចាត់ចែងលិខិតទៅតាមកម្មវត្ថុរបស់ម្ចាស់លិខិត។ លិខិតដែលចូលរដ្ឋបាលនៃរដ្ឋសភាត្រូវបែងចែកនីតិវិធីទៅតាមប្រភេទនៃតាមកម្មវត្ថុនៃលិខិត។ រាល់

[2] ប្រការ ១៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

លិខិតដែលស្នើសុំជួបពិគ្រោះយោបល់ជាមួយគណៈកម្មការជំនាញនានានៃរដ្ឋសភា ឬលិខិតផ្សេងៗស្នើសុំជួបអ្នកតំណាងរាស្ត្រ ត្រូវបានរដ្ឋបាលដាក់ជូនដោយផ្ទាល់ទៅគណៈកម្មការជំនាញ ឬតំណាងរាស្ត្រនោះ។

ដោយឡែកលិខិតដែលដាក់ស្នើសុំបញ្ហាផ្សេងៗ ដែលមិនទាក់ទងនឹងរដ្ឋសភា ប៉ុន្តែទាក់ទងគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាគឺរដ្ឋបាលសភាផ្ញើលិខិតទាំងនោះទៅជូនក្រុមតំណាងរាស្ត្រភាគច្រើន និងក្រុមតំណាងរាស្ត្រភាគតិចដើម្បីចាត់ចែងដាក់ជូនក្រុមតំណាងរាស្ត្រតាមគណបក្សរបស់ខ្លួន។

លិខិតផ្សេងៗដែលស្នើដាក់ជូនថ្នាក់ដឹកនាំកំពូលរបស់រដ្ឋសភា ឬជូនប្រធានរដ្ឋសភា រដ្ឋបាលបញ្ជូនមកអគ្គលេខាធិការដើម្បីត្រួតពិនិត្យ។ បន្ទាប់ពីការត្រួតពិនិត្យ អគ្គលេខាធិការដ្ឋានបញ្ជូលលិខិតទៅប្រធានរដ្ឋសភាដើម្បីសុំការអនុញ្ញាត ប្រសិនបើប្រធានរដ្ឋសភាពិនិត្យលិខិតរួចរាល់មិនមានបញ្ហា ប្រធានរដ្ឋសភានឹងចារបញ្ជូនលិខិតត្រឡប់មកអគ្គលេខាធិការដ្ឋានវិញដើម្បីធ្វើការទំនាក់ទំនងទៅសាមីម្ចាស់លិខិតដើម្បីឆ្លើយតបទៅតាមកម្មវត្ថុដែលបានស្នើសុំ។

ផ្ទុយពីដំណើរការខាងលើ ក្នុងរយៈពេលកន្លងមកគណៈកម្មាធិការខុមហ្វ្រែល បានដាក់លិខិតទៅអគ្គលេខាធិការនៃរដ្ឋសភាស្នើសុំសម្របសម្រួលបញ្ជូនលិខិតទាក់ទងប្រវត្តិរូបសង្ខេបអ្នកតំណាងរាស្ត្រទៅអ្នកតំណាងរាស្ត្រ និងករណីមួយទៀតគឺគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជាក៏បានដាក់លិខិតមួយទៅប្រធានរដ្ឋសភាដើម្បីស្នើសុំជួបពិភាក្សាជាមួយគណៈកម្មការទី១នៃរដ្ឋសភា ប៉ុន្តែលិខិតទាំងនោះត្រូវបានអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា មិនមានចាត់ការលើលិខិតនោះឡើយ។ ករណីមិនចាត់ការ ឬយឺតយ៉ាវក្នុងការឆ្លើយតបរបស់អគ្គលេខាធិការដ្ឋាននៃរដ្ឋសភាតែងតែកើតមានឡើងចំពោះលិខិតបញ្ជូនទៅរដ្ឋសភា។

### ៣.២ កិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា

នៅក្នុងអំឡុងពេលនេះ ខុមហ្វ្រែលអង្កេតឃើញថា សកម្មភាពទទួលបណ្តឹង និងកិច្ចអន្តរាគមន៍លើបណ្តឹងរបស់ប្រជាពលរដ្ឋរបស់រដ្ឋសភាសកម្មជាងរយៈពេលកន្លងមក។ មានបណ្តឹងរបស់ប្រជាពលរដ្ឋចំនួន០៦បណ្តឹង ដែលប្តឹងមករដ្ឋសភាដើម្បីឲ្យមានវិធានការរកដោះស្រាយបញ្ហាវិវាទនានា និងមានបណ្តឹងប្តឹងដោយផ្ទាល់ចំនួន ១ករណី។

#### ៣.២.១ ការចេញលិខិតអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ

នៅក្នុងរយៈពេលឆមាសដើមឆ្នាំទី២នេះ ខុមហ្វ្រែលទទួលទិន្នន័យអំពីការចេញលិខិតរបស់អ្នកតំណាងរាស្ត្រចំនួន ២២ច្បាប់ទៅគណៈកម្មការរដ្ឋសភា និងរាជរដ្ឋាភិបាលក្នុងគោលបំណងស្នើវិធានការ/អំពាវនាវឲ្យស្ថាប័នរាជរដ្ឋាភិបាល ដើម្បីចាត់វិធានការ ឬ/និងអន្តរាគមន៍ទៅលើបញ្ហានានារបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។

ក្នុងចំណោមលិខិតទាំង ២២ច្បាប់នោះ រួមមានលិខិតក្នុងគោលបំណងអំពាវនាវ/ស្នើចាត់វិធានការចំនួន ១៨ច្បាប់ និងលិខិតកោះហៅរដ្ឋមន្ត្រីមកបំភ្លឺក្នុងរដ្ឋសភា ខុមហ្វ្រែលទទួលទិន្នន័យបានតែ ៤ច្បាប់ប៉ុណ្ណោះ។ ចំពោះលិខិតទាំង២២ច្បាប់របស់អ្នកតំណាងរាស្ត្រ ខុមហ្វ្រែលបានទទួលព័ត៌មានមានលិខិតចំនួន ៤ច្បាប់មានការឆ្លើយតប ពីរាជរដ្ឋាភិបាល និងលិខិតចំនួន ៣ច្បាប់ត្រូវបានបដិសេធមិនធ្វើការបញ្ជូនដោយប្រធានរដ្ឋសភា។

ជាក់ស្តែងកាលពីថ្ងៃទី៩ ខែមិនា ឆ្នាំ២០១៥ លោក ហេង សំរិន ប្រធានរដ្ឋសភាបានបដិសេធមិនបញ្ជូនលិខិតរបស់អ្នកតំណាងរាស្ត្រ អ៊ុំ សំអាន មណ្ឌលសៀមរាប ពីគណបក្សសង្គ្រោះជាតិ ដែលស្នើសុំឲ្យរដ្ឋាភិបាលបញ្ឈប់កិច្ចសន្យាសម្បទានឲ្យក្រុមហ៊ុន សុខា អូតែល របស់ឧកញ៉ា សុខ គង់ ក្នុងការប្រមូលចំណូលពីការលក់ប័ណ្ណឲ្យភ្ញៀវទេសចរបរទេសចូលទស្សនាអង្គរ។ លោក ហេង សំរិន បដិសេធមិនបញ្ជូលលិខិតនោះ ដោយបានចារថា *«ខ្ញុំគិតថា កិច្ចការនេះទុកឲ្យគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសវនកម្ម នៃរដ្ឋសភាជាអ្នកធ្វើវិញ»*។

មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញចែងថា *«តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា»*។ យោងតាមមាត្រាគ្មានលក្ខខណ្ឌណាមួយដែលប្រធានរដ្ឋសភាមានសិទ្ធិបដិសេធក្នុងការបញ្ជូនលិខិតរបស់តំណាងរាស្ត្រទៅរដ្ឋាភិបាលនោះទេ។ ករណីនេះគឺជាការប្រើសិទ្ធិអំណាចជាប្រធានសភាហួសព្រំដែន។

ខ្លឹមសារក្នុងលិខិតបានបញ្ជាក់ថា ផ្អែកលើការគណនារបស់លោក ចំណូលពីការលក់ប័ណ្ណឲ្យភ្ញៀវទេសចរបរទេសចូលទស្សនាអង្គរវត្តសម្រាប់ឆ្នាំ២០១៤ គួរតែទទួលបាន១៤៤លានដុល្លារ មិនមែន៥៩លានដុល្លារ ដូចរបាយការណ៍របស់អាជ្ញាធរជាតិអប្សរានោះទេ ដែលចំនួននេះខុសគ្នាដល់ទៅ៨៥លានដុល្លារ។

លិខិតដ៏កម្រមួយទៀតគឺលិខិតរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលបានកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ លោក ប៊ូ ឡាំ តំណាងរាស្ត្រមណ្ឌលខេត្តរតនគិរី បានស្នើទៅប្រធានគណៈកម្មការទី៤នៃរដ្ឋសភាឲ្យផ្លាស់ប្តូរតំណែងលោក អ៊ុក សំអុល អភិបាលក្រុងបានលុងបន្ទាប់ពីទទួលបណ្តឹងពីប្រជាពលរដ្ឋផ្ទាល់រឿងការប្រើអំណាចបំពានលើប្រជាពលរដ្ឋ។ ជុំវិញលិខិតអន្តរាគមន៍នេះ ត្រូវបាន លោកហ៊ុន ណេង ប្រធានគណៈកម្មការទី៤នៃរដ្ឋសភា លើកឡើងថា លោកមិនមានភារកិច្ចចាត់ចែងការសំណុំរឿងនេះទេ ដោយលើកហេតុផលថាកិច្ចការដកហូតដំណែងនេះ គឺជាភារៈរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។ គួរបញ្ជាក់ថា នេះលើកទី១ហើយ ដែលតំណាងរាស្ត្រមកពីគណបក្សប្រជាជនស្នើឲ្យដកតំណែងជាមន្ត្រីមកគណបក្សកាន់អំណាចដូចគ្នា។

## IV. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### ៤.១ អ្នកនាំពាក្យរបស់រដ្ឋសភា

កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ រដ្ឋសភាបានសម្រេចបង្កើតឱ្យមានអ្នកនាំពាក្យជាផ្លូវការរបស់ខ្លួន ដែលមានលោក ឈាង វុន ប្រធានគណៈកម្មការទី៥នៃរដ្ឋសភា ជាអ្នកនាំពាក្យ និងលោកស្រី ជូឡុង សូម្ម៉ាអនុប្រធានគណៈកម្មការទី៥នៃរដ្ឋសភា ជាអ្នកនាំពាក្យបម្រុង។ ក្នុងសេចក្តីសម្រេចនោះបានបញ្ជាក់អំពីតួនាទី និងភារកិច្ចរបស់អ្នកនាំពាក្យ ក្នុងការរៀបចំឯកសារផ្សព្វផ្សាយព័ត៌មាន និងធ្វើការបំភ្លឺជូនសាធារណជនចំពោះព្រឹត្តិការណ៍ និងសភាពការណ៍នយោបាយជាតិ និងអន្តរជាតិសំខាន់ៗមកលើរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ជុំវិញការបង្កើតអ្នកនាំពាក្យនៅរដ្ឋសភានេះ ការសង្កេតឃើញថា ហាក់មិនបានឈរលើគោលការណ៍វិជ្ជាជីវៈត្រឹមត្រូវក្នុងការតែងតាំងអ្នកនាំពាក្យនោះទេ។ រដ្ឋសភានីតិកាលទី៥នេះ មានគណបក្សនយោបាយចំនួនពីរទទួលបានអាសនៈ ដូច្នេះអ្នកនាំពាក្យនៃរដ្ឋសភាគួរតែជាមនុស្សដែលវិជ្ជាជីវៈសារព័ត៌មាន ដែលមិនមែនអ្នកតំណាងរាស្ត្រនៃគណបក្សណាមួយដែលមានអាសនៈក្នុងរដ្ឋសភានោះទេ។ ជារឿយៗលោក ឈាង វុន តែងតែធ្វើសន្និសីទសារព័ត៌មាន ដើម្បីឆ្លើយតបទៅនឹងមតិរិះគន់ និងការចោទប្រកាន់នានាមកលើថ្នាក់ដឹកនាំរដ្ឋសភាមកពីគណបក្សប្រជាជនកម្ពុជា ពិសេសការចោទប្រកាន់ធ្វើឡើងដោយអ្នកតំណាងរាស្ត្រនៃគណបក្សប្រឆាំង។ ត្រង់ចំណុចសបញ្ជាក់ឲ្យឃើញថា ការបំពេញភារកិច្ចការងារក្នុងនាមជាអ្នកនាំពាក្យគឺធ្វើដើម្បីការពារតែផលប្រយោជន៍គណបក្សខ្លួន មិនមែនដើម្បីប្រយោជន៍រួមនោះទេ។

### ៤.២ អនុប្រធានទី១ នៃរដ្ឋសភាទទួលរងការគំរាមកំហែង

លោក គឹម សុខា អនុប្រធានទី១នៃរដ្ឋសភាមកពីគណបក្សសង្គ្រោះជាតិ តែងត្រូវបានមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន កម្ពុជា ពិសេសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រមានចាត់វិធានការលើរូបលោក ទាក់ទងទៅនឹងការដឹកនាំបាតុកម្មនៅក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតីកាលទី៥ ឆ្នាំ២០១៣ និងសារដែលលោកបានថ្លែងទៅកាន់អ្នកគាំទ្រនៅក្រៅ

ប្រទេស។ សកម្មភាព និងពាក្យសម្ដីរបស់លោក កឹម សុខា ត្រូវបានមន្ត្រីគណបក្សប្រជាជនកម្ពុជាលើកឡើងថា ជាគម្រោងផ្ដួលរំលំរដ្ឋាភិបាលនៅក្រោយការបោះឆ្នោត។ ទាក់ទងការចោទប្រកាន់នេះដែរ លោក កឹម សុខា តែងតែធ្វើការបដិសេធថា លោកមិនបានប្រើពាក្យ និងធ្វើសកម្មភាពដើម្បីផ្ដួលរំលំរដ្ឋាភិបាលនោះទេ ប៉ុន្តែគឺក្នុងន័យផ្លាស់ប្ដូរ ហើយការផ្លាស់នោះគឺធ្វើឡើងដោយសន្តិវិធី និងអហិង្សា។

ជុំវិញបញ្ហានេះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានខ្លាំងៗថា នឹងវាយខ្ទោះលោក កឹម សុខា បើសិនលោកដឹកនាំបាតុកម្មឲ្យដោះលែងសកម្មជនគណបក្សសង្គ្រោះជាតិ ដែលជាប់ពន្ធនាគារពាក់ព័ន្ធនឹង បាតុកម្មនៅក្រោយការបោះឆ្នោតឆ្នាំ២០១៣។ លោកនាយករដ្ឋមន្ត្រីក៏បានរំឮកថា កន្លងមកអាជ្ញាធរមានសមត្ថកិច្ចមានគម្រោងចាប់ខ្លួនលោក កឹម សុខា ផងដែរ តែដោយសារពេលនោះអត់មានមូលដ្ឋានច្បាប់រឹងមាំ។

បន្ទាប់ពីការព្រមានពីសំណាក់លោកនាយករដ្ឋមន្ត្រី តុលាការបានចេញដីកាកោះហៅលោក កឹម សុខាឲ្យចូលបំភ្លឺនៅតុលាការ។ ការកោះហៅនោះធ្វើឡើងទាំងរូបលោកមានអភ័យឯកសិទ្ធិតំណាងរាស្ត្រ។ ករណីត្រូវបានមើលឃើញថា ចំណាត់ការរបស់តុលាការហាក់ធ្វើឡើងក្រោមសម្ពាធនយោបាយរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល ហើយតុលាការមិនបានអនុវត្តត្រឹមត្រូវតាមនីតិវិធីច្បាប់ ព្រោះមិនបានស្នើទៅរដ្ឋសភាតាមរយៈក្រសួងយុត្តិធម៌ឲ្យលើកអភ័យឯកសិទ្ធិលោក កឹម សុខា មុននឹងអនុវត្តនីតិវិធីរបស់ខ្លួន។

ដោយលោក កឹម សុខា នៅបន្តធ្វើការរិះគន់ភាពអសកម្ម និងភាពអវិជ្ជមានរបស់រដ្ឋាភិបាល ឬស្ថាប័នរដ្ឋនោះ ថ្នាក់ដឹកនាំ គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចបានគំរាមជាបន្តបន្ទាប់ថា គណបក្សខ្លួននឹងធ្វើការបោះឆ្នោតទម្លាក់ លោក កឹម សុខា ពីតំណែងជាអនុប្រធានទី១រដ្ឋសភា ព្រោះលោកថា កៅអីអនុប្រធានទី១រដ្ឋសភាដែល លោក កឹម សុខា កំពុងតែអង្គុយនេះ បានមកដោយមានការរួមចំណែកសំឡេងគាំទ្ររបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។

ការគំរាមកំហែងនេះត្រូវបានគេមើលឃើញថា ជាយុទ្ធសាស្ត្រដើម្បីបំបាក់ស្មារតីលោក កឹម សុខា និងសកម្មជនគណបក្សប្រឆាំងឯទៀត ដែលនៅបន្តធ្វើការរិះគន់លោក ហ៊ុន សែន និងរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥នេះ ហើយវាជារឿងនយោបាយសុទ្ធសាធ។

### ៤.៣ ករណីលាលែងពីតំណាងរាស្ត្ររបស់លោក វ៉ាន សំអឿន

លោក វ៉ាន សំអឿន ជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពត ពីគណបក្សសង្គ្រោះជាតិ បានផ្ញើលិខិតមួយច្បាប់ជូនប្រធាន រដ្ឋសភាស្នើសុំលាលែងពីអ្នកតំណាងរាស្ត្រ។ លោកបានលើកមូលហេតុថា លោកគ្មានឱកាសនឹងបម្រើប្រទេសជាតិតាមឆន្ទៈ និងបទពិសោធន៍របស់ខ្លួន។

បើទោះជាមានដាក់ការសង្ស័យថា លោកចាកចេញដើម្បីជាថ្នូរនឹងផលប្រយោជន៍អ្វីមួយពីគណបក្សកាន់អំណាច ប៉ុន្តែនេះ ជាគំរូដែលបញ្ជាក់ពីតម្លាភាពក្នុងការលាឈប់ពីតំណាងរាស្ត្ររបស់លោក។ ការផ្លាស់តំណាងរាស្ត្រក្នុងរយៈពេលកន្លងមកត្រូវបានមើលឃើញថា ធ្វើឡើងតាមឆន្ទៈរបស់ប្រធានគណបក្ស ហើយការផ្លាស់ប្ដូរទៀតសោត គឺមិនបញ្ជាក់អំពីមូលហេតុច្បាស់លាស់ពីសាមីខ្លួនដែលលាឈប់នោះទេ។

### ៤.៤ លោក សុន ឆ័យ រងការចោទប្រកាន់ថាធ្វើឲ្យល្អក់កករនៅក្នុងរដ្ឋសភា

លោក សុន ឆ័យ អនុប្រធានគណៈកម្មការទី២នៃរដ្ឋសភា ត្រូវបានថ្នាក់ដឹកនាំរដ្ឋសភាពីគណបក្សប្រជាជនកម្ពុជាចោទប្រកាន់ថា លោកកំពុងធ្វើឲ្យមានភាពល្អក់កករដល់ទំនាក់ទំនងគណបក្សទាំងពីរ។ លោក ឈាង វុន អ្នកនាំពាក្យរបស់រដ្ឋសភាបានរៀបចំសន្និសីទសារព័ត៌មានដើម្បីច្រានចោលរាល់ការចោទប្រកាន់របស់លោក សុន ឆ័យ ទាក់ទងបញ្ហាមិនប្រក្រតី

ក្នុងការចាយវាយថវិការបស់រដ្ឋសភា ដោយលើកឡើងថា ការចោទប្រកាន់ទាំងនោះគឺគ្មានមូលដ្ឋានត្រឹមត្រូវ។ ជាមួយគ្នានេះ លោក សុន ឆ័យ ទទួលការគំរាមថា រដ្ឋសភាអាចនឹងដកចេញពីតួនាទីអនុប្រធានគណៈកម្មការទី២ ប្រសិនលោកនៅបន្តធ្វើការចោទប្រកាន់រដ្ឋសភា។ ជាមួយគ្នានេះលោក ជាម យៀប ប្រធានគណៈកម្មការទី២ ក៏បានធ្វើសន្និសីទសារព័ត៌មាន ដើម្បីការពារអគ្គលេខាធិការដ្ឋាននៃរដ្ឋសភាថា ការប្រើប្រាស់ថវិកាកន្លងមករបស់រដ្ឋសភាគឺត្រឹមត្រូវ ហើយលោកបានស្នើប្រធានរដ្ឋសភាធ្វើការណែនាំលោក សុន ឆ័យ ដោយលោកចោទប្រកាន់ថា បានធ្វើខុសបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

ជុំវិញការចោទប្រកាន់នេះលោក សុន ឆ័យ បានអះអាងលោកមិនបានធ្វើខុសនីតិវិធី ហើយអ្វីដែលលោកចោទប្រកាន់គឺមានការសិក្សាច្បាស់លាស់ ហើយលោកតែងតែទាមទារសុំឲ្យអគ្គលេខាធិការរដ្ឋសភាផ្តល់ឯកសារចំណាយទាំងនោះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ ប៉ុន្តែមិនមានការឆ្លើយតបទេ បើទោះបីជាលោកបានស្នើសុំអន្តរាគមន៍ពីប្រធានរដ្ឋសភា។ លោកក៏ធ្លាប់បានស្នើឲ្យគណៈកម្មការទី២នៃរដ្ឋសភា និងអង្គភាពប្រឆាំងអំពើពុករលួយ ធ្វើការស៊ើបអង្កេតការប្រើប្រាស់ថវិកានេះដែរកន្លងមក ប៉ុន្តែមិនទាន់មានការស៊ើបអង្កេតនៅឡើយ ហើយថ្នាក់ដឹកនាំរដ្ឋសភាតែងតែចេញមុខការពារថា ការចាយវាយរបស់រដ្ឋសភាកន្លងមកគឺត្រឹមត្រូវ និងគ្មានអំពើពុករលួយនោះទេ។

### ៤.៥ ការអនុវត្តនីតិវិធីរបស់តុលាការលើអ្នកតំណាងរាស្ត្រមានអភ័យឯកសិទ្ធិជាការរំលោភច្បាប់

កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៤ សាលាដំបូងរាជធានីភ្នំពេញបានចាប់ខ្លួនឃុំខ្លួន និងធ្វើការចោទប្រកាន់ បេក្ខជនជាប់ឆ្នោតប្រាំពីរ(៧)រូប នៃគណបក្សសង្គ្រោះជាតិ និងបានចោទប្រកាន់ពីបទផ្តើមគំនិតឲ្យមានកុបកម្ម ដឹកនាំធ្វើកុបកម្មហឹង្សាមានស្ថានទម្ងន់ទោស និងបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ការឃុំខ្លួន និងការចោទប្រកាន់គឺពាក់ព័ន្ធទៅនឹងបាតុកម្មទាមទារឱ្យមានការដោះលែងទីលានប្រជាធិបតេយ្យ ដែលបង្កឲ្យមានអំពើហឹង្សាមួយបានកើតឡើង។

ជុំវិញការឃុំខ្លួននៅពេលនោះ មានការលើកឡើងអំពីអភ័យឯកសិទ្ធិសភារបស់បេក្ខជនជាប់ឆ្នោតទាំងនោះ ដែលថាបើពួកគេមានអភ័យឯកសិទ្ធិ ការអនុវត្តនីតិវិធីរបស់តុលាការគឺរំលោភច្បាប់ ប៉ុន្តែក្នុងន័យនេះពួកគេមិនមានអភ័យឯកសិទ្ធិទេ ដូច្នេះការបង្កើតរដ្ឋសភានៅក្រោយការបោះឆ្នោតគឺមិនស្របច្បាប់។

អ្នកទាំងនោះត្រូវបានដោះលែងវិញភ្លាមៗ នៅបន្ទាប់ពីកិច្ចចរចាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ប៉ុន្តែតុលាការនៅបន្តនីតិវិធីរបស់ខ្លួន ដោយបានកោះហៅអ្នកទាំងនោះទៅបំភ្លឺនៅតុលាការនៅក្រោយកិច្ចព្រមព្រៀង ហើយអ្វីគួរឲ្យកត់សម្គាល់នោះគឺការកោះហៅនោះបន្ទាប់ពីតំណាងរាស្ត្រទាំងនោះទទួលបានអភ័យឯកសិទ្ធិសភា។

ការអនុវត្តរបស់តុលាការនេះត្រូវបានមើលឃើញថា រំលោភរដ្ឋធម្មនុញ្ញត្រង់មាត្រា៨០ ដែលចែងថា "តំណាងរាស្ត្រមានអភ័យឯកសិទ្ធិ។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ដោយហេតុផលបានសម្តែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួននោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍របស់សភា...។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។"

ជាការកត់សម្គាល់ ការកោះហៅតំណាងរាស្ត្របក្សប្រឆាំងឲ្យចូលបំភ្លឺនៅតុលាការជាបន្តបន្ទាប់ ទាក់ទងនឹងសំណុំរឿងអំពើហឹង្សានៅជិតទីលានប្រជាធិបតេយ្យ បានធ្វើឡើងបន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រមានលុបចោលវប្បធម៌សន្ទនា បើអនុប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា នៅបន្តរិះគន់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។

ករណីមួយដោយឡែកទៀត គឺបានកើតឡើងនៅក្នុងអំឡុងខែមីនា ឆ្នាំ២០១៤ ចំពោះអ្នកតំណាងរាស្ត្រ ចាន់ ចេង មណ្ឌលខេត្តកណ្ដាលនៃគណបក្សសង្គ្រោះជាតិ ដែលត្រូវបានសាលាដំបូងខេត្តកណ្ដាលផ្ដន្ទាទោសដោយកំបាំងមុខឲ្យជាប់ពន្ធនាគារ២ឆ្នាំ ពីបទផ្ដល់មធ្យោបាយលួចរត់ដល់មន្ត្រីមូលដ្ឋានម្នាក់របស់គណបក្សនេះពីការឃុំខ្លួនកាលពី ឆ្នាំ២០១១ កន្លងមក។ ការផ្ដន្ទាទោសនេះធ្វើឡើងទាំងអ្នកតំណាងរាស្ត្ររូបនេះមានមានអភ័យឯកសិទ្ធិសភា។

ជារួមអ្នកវិភាគ និងឃ្លាំមើលសិទ្ធិមនុស្សបានហៅការកោះហៅ និងការផ្ដន្ទាទោសរបស់តុលាការក្នុងសំណុំរឿងទាំងនេះ គឺរំលោភច្បាប់ ហើយវាជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ ដោយតុលាការចង់បន្តនីតិវិធីដើម្បីដាក់សម្ពាធទៅលើគណបក្សប្រឆាំង។

### ៤.៦ តំណាងរាស្ត្រ និងបញ្ហាព្រំដែន

បញ្ហាព្រំដែនជាមួយប្រទេសជិតខាង ពិសេសប្រទេសវៀតណាមជាបញ្ហាក្ដៅដែលក្រុមអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពខ្លាំងក្នុងរយៈពេលចុងក្រោយនេះ។ សកម្មភាពទាំងនោះរួមមានការចុះពិនិត្យដល់ទីកន្លែងដែលមានការរំលោភចូលដោយភាគីវៀតណាម និងការស្នើឲ្យមានការបំភ្លឺ និងធ្វើការដោះស្រាយពីរាជរដ្ឋាភិបាលតាមយន្តការរដ្ឋសភាជាដើម។ បញ្ហាព្រំដែននេះ ត្រូវបានគណបក្សប្រឆាំងរកឃើញថា ប្រទេសវៀតណាមបានរំលោភចូលទឹកដីកម្ពុជា ដូចជាករណី នៅច្រកដាក់ដាំ ខេត្តមណ្ឌលគិរី នៅខ្សែបន្ទាប់រវាងកម្ពុជា-វៀតណាមក្នុងខេត្តស្វាយរៀង នៅឃុំកក់ ស្រុកពញាក្រែក និងភូមិជើង ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងព្រមទាំងនៅច្រកទាន់ហាន់ ឃុំព្រៃកគ្រីស ស្រុកកំពង់ត្រាច ខេត្តកំពតជាដើម។

ជាក់ស្ដែង ក្រុមអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានដឹកនាំក្រុមការងារចុះពិនិត្យនៅតាមព្រំដែន និងធ្វើសកម្មភាពមួយចំនួនដូចជា៖

- ថ្ងៃទី២៦ ខែមេសា ចុះទៅពិនិត្យតំបន់ព្រំដែនកម្ពុជា-វៀតណាម នៅត្រង់បង្គោលឡាក់លេខ១២៥ និង១៣០ ស្ថិតក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
- នៅថ្ងៃទី០៣ និងថ្ងៃទី២៧ ខែឧសភា ចុះពិនិត្យករណីវៀតណាមធ្វើផ្លូវរំលោភចូលដីកម្ពុជាក្នុងឃុំដូង ស្រុកចន្ទ្រា និងនៅឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។
- ថ្ងៃទី១៤ ខែឧសភា ចុះពិនិត្យការជីកព្រែកចូលដីកម្ពុជាពីភាគីវៀតណាមនៅឃុំព្រៃកគ្រីស ស្រុកកំពង់ត្រាច ខេត្តកំពត។ ករណីនេះ អ្នកតំណាងរាស្ត្រក៏បានធ្វើលិខិតទៅរដ្ឋាភិបាលឲ្យធ្វើការឆ្លើយបំភ្លឺ តែត្រូវបានតំណាងរដ្ឋាភិបាលបដិសេធ ដោយលើកឡើងថា ការចោទប្រកាន់អំពីការរំលោភនោះគ្មានមូលដ្ឋានច្បាស់លាស់។
- ថ្ងៃទី២៨ ខែឧសភា បានធ្វើលិខិតទៅលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ឲ្យផ្ដល់ព័ត៌មានពីឈ្មោះភូមិចំនួនពីរដែលត្រូវដោះដូរទៅឲ្យវៀតណាម ជំនួសភូមិពីរដែលជាភូមិកំណើតរបស់ប្រធានរដ្ឋសភា លោក ហេង សំរិន។ ចំពោះសំណើនេះលោក ហ៊ុន សែន បានឆ្លើយតបតាមរយៈលិខិតចុះថ្ងៃទី១៤ ខែមិថុនាថា លោកធ្លាប់បានបញ្ជាក់រួចហើយកាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ ២០១២ កន្លងមក នៅក្នុងការឆ្លើយបំភ្លឺរបស់ខ្លួនជាង៥ម៉ោងនៅរដ្ឋសភា។
- ថ្ងៃទី៣១ ខែឧសភា ចុះពិនិត្យករណីអាជ្ញាធរ និងពលរដ្ឋវៀតណាមបាញ់ថ្នាំបំផ្លាញផលដំណាំកសិករខ្មែរនៅភូមិជើង ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ករណីនេះ រដ្ឋមន្ត្រីក្រសួងការបរទេសលោក ហោ ណាំហុង បានធ្វើលិខិតបំភ្លឺទៅប្រធានរដ្ឋសភាថា កសិករខ្មែរបានដាំដំណាំលើទឹកដីវៀតណាម។
- ថ្ងៃទី០២ ខែមិថុនា បានដាក់លិខិតទៅលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ស្នើសុំឲ្យពិនិត្យមើលព្រំដែននៅភ្នំជិន ក្នុងស្រុកគិរីវង់ ខេត្តតាកែវ ដោយលោកអះអាងថា វៀតណាមបានរំកិលព្រំដែនចូលមកទឹកដីកម្ពុជា។

- ថ្ងៃទី០៣ ខែមិថុនា បានផ្ញើលិខិតស្នើសុំឲ្យរដ្ឋាភិបាលផ្តល់ផែនទីដែលត្រូវបានប្រើប្រាស់សម្រាប់បោះបង្គោលព្រំដែន កម្ពុជា វៀតណាម និងស្នើពន្យល់លម្អិតអំពីនីតិវិធីនៃដំណើរការបោះបង្គោលព្រំដែន។ ជុំវិញសំណើនេះនៅថ្ងៃទី១០ គណៈកម្មាធិការព្រំដែនកម្ពុជាបានបដិសេធក្នុងការផ្តល់ផែនទីផ្លូវការទៅតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និងបានបញ្ជាក់ថា រាជរដ្ឋាភិបាលធ្លាប់បានឆ្លើយបំភ្លឺច្រើនលើកច្រើនសាហើយ អំពីការបោះបង្គោលព្រំដែនទៅរដ្ឋសភា។
- ថ្ងៃទី០៨ ខែមិថុនា ចុះពិនិត្យទីតាំងដែលវៀតណាមជីករណ្តៅស្រះទឹក ក្នុងដីដែលត្រួតស៊ីគ្នា រវាងព្រំដែនកម្ពុជា-វៀតណាម នៅចំណុចភូមិឡំ ឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។ ករណីនេះរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា លោក ហោ ណាំហុង នៅទី១៦ បានផ្ញើលិខិតមួយទៅប្រធានរដ្ឋសភា លោក ហេង សំរិន បញ្ជាក់ប្រាប់ថារាជរដ្ឋាភិបាលបានដាក់កំណត់ទូតទៅរដ្ឋាភិបាលវៀតណាមអំពីការឈ្លានពានរបស់វៀតណាមមកលើដីកម្ពុជា នៅតំបន់នោះរួចហើយ។
- ថ្ងៃទី២០ ខែមិថុនា ចុះពិនិត្យមើលព្រំដែនកម្ពុជា-វៀតណាម ដែលត្រូវចោទថា ភាគីវៀតណាមជីកដីធ្វើគ្រឹះសម្រាប់ការសាងសង់ប៉ុស្តិ៍យោធារបស់ខ្លួនចូលទឹកដីកម្ពុជា នៅជាប់ភូមិព្រៃកស្បូវ ស្រុកកោះធំ ខេត្តកណ្តាល។
- ថ្ងៃទី២៥ ខែមិថុនា បានចេញសេចក្តីប្រកាសព័ត៌មានមួយទាមទារឲ្យរដ្ឋាភិបាលកម្ពុជាបង្កើតគណៈកម្មាធិការចម្រុះមួយ ដែលមានការចូលរួមពីគណបក្សមានអាសនៈក្នុងសភា និងអ្នកជំនាញពាក់ព័ន្ធ ដើម្បីអាចចូលរួមដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម និងទាមទារឲ្យរដ្ឋាភិបាលយកករណីនេះទៅតុលាការយុត្តិធម៌អន្តរជាតិ។
- ថ្ងៃទី២៨ ខែមិថុនា ចុះពិនិត្យបង្គោលព្រំដែនលេខ ២០៣ ស្ថិតនៅភូមិធ្លក ឃុំត្នោត ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។ ក្នុងអំឡុងពេលចុះពិនិត្យនោះអំពើហិង្សាមួយបានកើតឡើងពីសំណាក់ប្រជាពលរដ្ឋវៀតណាម បានបណ្តាលឲ្យអ្នកតំណាងរាស្ត្រ និងប្រជាពលរដ្ឋមួយចំនួនរងរបួស។ ជុំវិញការប្រើអំពើហិង្សានេះក្រុមតំណាងរាស្ត្រគណបក្សប្រឆាំងបានស្នើចំណាត់ការពីរដ្ឋាភិបាល ប៉ុន្តែមិនទាន់ឃើញមានចំណាត់ការណាមួយនៅឡើយ។ ដោយឡែក អាជ្ញាធរខេត្តស្វាយរៀងបានចេញលិខិតមួយ ប្រកាសមិនទទួលខុសត្រូវតាមផ្លូវច្បាប់លើការប៉ះទង្គិចនៅតាមព្រំដែនរវាងប្រជាពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋវៀតណាម ដោយអះអាងថា ក្រុមប្រជាពលរដ្ឋចុះពិនិត្យព្រំដែនមិនបានជូនដំណឹងអាជ្ញាធរខេត្តជាមុន។

មានការមើលឃើញថា កិច្ចការព្រំដែនកន្លងមក ក្លាយជារឿងសំងាត់របស់រដ្ឋាភិបាល ដោយមិនឲ្យភាគីពាក់ព័ន្ធនានាចូលរួម។ ដោយមិនមានការបើកចំហ និងបង្ហាញនីតិវិធីត្រឹមត្រូវដល់ភាគីពាក់ព័ន្ធពីការងាររបស់រដ្ឋាភិបាលក្នុងបញ្ហានេះ វាបានធ្វើឲ្យមានការមិនជឿទុកចិត្ត និងបានដាក់ការសង្ស័យថាកម្ពុជាបានខាតបង់ទឹកដីឲ្យប្រទេសវៀតណាម នៅស្របពេលដែលប្រជាពលរដ្ឋរស់នៅតាមបន្ទាត់ព្រំដែនបានលើកឡើងពីការរំលោភចូលទឹកដីកម្ពុជាពីភាគីវៀតណាមផងនោះ។ បញ្ហាមួយទៀត គឺមន្ត្រីជំនាញព្រំដែនរដ្ឋាភិបាលធ្លាប់បានលើកឡើងថា រឿងព្រំដែនជាការងាររបស់រដ្ឋាភិបាល មិនមែនជាការងាររបស់ស្ថាប័ននីតិប្បញ្ញត្តិទេ។ ការលើកឡើងបែបនេះជាការទាត់ចោលតួនាទីរបស់ស្ថាប័នកំពូលរបស់ជាតិ ដែលជាស្ថាប័នតំណាងឲ្យប្រជាពលរដ្ឋ និងជាអ្នកត្រួតពិនិត្យការងាររបស់រដ្ឋាភិបាល។

ដើម្បីដោះស្រាយបញ្ហា និងអាចទទួលយកបានពីភាគីពាក់ព័ន្ធនោះ រដ្ឋាភិបាលត្រូវតែដោះស្រាយបញ្ហាព្រំដែនដោយបើកចំហ និងមានតម្លាភាព ដែលមានការចូលរួមពីគណបក្សប្រឆាំង អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ហើយមិនត្រូវឆ្លើយទាំងប្រញាប់ប្រញាល់ ថាព្រំដែនដែលមានជម្លោះនោះ ជារបស់ប្រទេសណាមួយនោះទេ ផ្ទុយទៅវិញត្រូវតែបង្កើតគណៈកម្មការចម្រុះត្រួតពិនិត្យតំបន់ជម្លោះនោះ។

### ៤.៧ ការខ្វែងគំនិតគ្នាក្នុងការកោះហៅមន្ត្រីរដ្ឋាភិបាលឲ្យចូលបំភ្លឺក្នុងរដ្ឋសភា

ការដោះស្រាយជម្លោះដីធ្លីមានភាពយឺតយ៉ាវ និងថែមទាំងមានអំពើហឹង្សាទៀតនោះ បានជំរុញឲ្យរដ្ឋសភាមានគម្រោងកោះហៅអភិបាលខេត្តក្រចេះទៅឆ្លើយបំភ្លឺនៅរដ្ឋសភា។ គម្រោងនេះត្រូវបានសង្គមស៊ីវិលធ្វើការលើបញ្ហាដីធ្លី និងពលរដ្ឋមានជម្លោះបានបង្ហាញការគាំទ្ររបស់ខ្លួនចំពោះយន្តការនេះ ដោយពួកគេយល់ថា វាអាចជំរុញអាជ្ញាធរខេត្តដោះស្រាយជម្លោះដោយមានប្រសិទ្ធភាព និងគោរពសិទ្ធិមនុស្ស។

គណៈកម្មការទី ១ នៃរដ្ឋសភា បានដាក់លិខិតទៅកាន់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមរយៈប្រធានរដ្ឋសភា កាលពីថ្ងៃទី ១៩ ឧសភា ស្នើសុំកោះហៅអភិបាលខេត្តក្រចេះ លោក សរ ចំរុង មកឆ្លើយបំភ្លឺនៅរដ្ឋសភាអំពីបញ្ហាទំនាស់ដីធ្លី ដែលកំពុងកើតមានជាច្រើនករណីក្នុងខេត្តនេះ។ ចំណែកឯគណៈកម្មការទី១០ ក៏បានដាក់លិខិតទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ៧ ឧសភាផងដែរ ដើម្បីកោះហៅអភិបាលស្រុកល្វាឯម ខេត្តកណ្តាល ទៅឆ្លើយបំភ្លឺពីបញ្ហាពុករលួយ ក្រោយពីទទួលគណៈកម្មការបានទទួលបណ្តឹងពីប្រជាពលរដ្ឋ។

ប៉ុន្តែសំណើទាំងនេះត្រូវបានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានបដិសេធសំណើទាំងនេះតាមរយៈលិខិតទៅកាន់រដ្ឋសភា កាលពីថ្ងៃទី២៦ ខែឧសភា ដោយបញ្ជាក់ថា អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានកាតព្វកិច្ចទទួលខុសត្រូវចំពោះមុខរដ្ឋសភាទេ។ ខ្លឹមសារក្នុងលិខិតនោះលើកឡើងថា យោងតាមមាត្រា ១២១ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចែងថា សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត។

ជុំវិញការបដិសេធនេះគណៈកម្មការពាក់ព័ន្ធរបស់រដ្ឋសភាបានឆ្លើយតបថា បញ្ហាទំនាស់ដីធ្លី និងការដោះស្រាយ ព្រមទាំងការចោទប្រកាន់ពីបញ្ហាពុករលួយបានកើតឡើងនៅអាជ្ញាធរថ្នាក់ខេត្ត និងស្រុក ដូច្នេះគួរតែអ្នកទាំងនោះមកបំភ្លឺដោយផ្ទាល់នៅរដ្ឋសភា។ គណៈកម្មការរដ្ឋសភាក៏គ្រោងកោះហៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតែម្តងដែលជាអាណាព្យាបាលរបស់អាជ្ញាទាំងនោះ។

### ៤.៨ សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីអាចប៉ះពាល់ដល់ការស្វែងរកដំណោះស្រាយរបស់ រដ្ឋសភា

សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី៥ ខែមិថុនា មានខ្លឹមសារថា គ្រប់ក្រសួង ស្ថាប័ន អង្គភាព សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈនានា មុននឹងទទួលជួប ឬទៅបំភ្លឺនៅគណៈកម្មការនានារបស់ស្ថាប័ននីតិបញ្ញត្តិ ឬក្រុមតំណាងរាស្ត្រ ដើម្បីសិក្សា ឬស្វែងយល់ និងផ្តល់ព័ត៌មាននានា ត្រូវមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នដែលជាសមាជិករាជរដ្ឋាភិបាល។ លិខិតបញ្ជាក់បន្ថែមថា ចំពោះការសុំបំភ្លឺ សុំឯកសារ សុំរបាយការណ៍ សុំព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ ឬពាក់ព័ន្ធនឹងពាក្យប្តឹងចោទប្រកាន់អំពើពុករលួយ ត្រូវគោរពតាមច្បាប់ប្រឆាំងអំពើពុករលួយ និងលិខិតបទដ្ឋានគតិយុទ្ធនានា។

ជុំវិញសេចក្តីជូនដំណឹងនេះត្រូវបានអ្នកតំណាងរាស្ត្រ និងជាថ្នាក់ដឹកនាំគណៈកម្មការជំនាញរដ្ឋសភាពីគណបក្សសង្គ្រោះជាតិបានឆ្លើយតបថា វាប៉ះពាល់ដល់តួនាទីរបស់រដ្ឋសភា ហើយធ្វើឲ្យរដ្ឋសភាកាន់តែចង់ដឹងថាតើមានអ្វីដែលស្ថាប័ននីតិប្រតិបត្តិលាក់បាំងបានជារឹតត្បិតមន្ត្រីរបស់ខ្លួនក្នុងការធ្វើសេចក្តីរាយការណ៍បែបនេះ និងជាចេតនារឹតត្បិតសិទ្ធិរបស់តំណាងរាស្ត្រ ក្នុងការស្នើនូវព័ត៌មាននានា និងពាក់ព័ន្ធអំពើពុករលួយ។

អ្នកឃ្លាំមើលយល់ឃើញថា រដ្ឋាភិបាលមិនគួរហៅមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទៅបំភ្លឺ ឬផ្តល់ព័ត៌មានជូនរដ្ឋសភាទេព្រោះការសហការរវាងមន្ត្រីរដ្ឋាភិបាល និងរដ្ឋសភាគឺដើម្បីដោះស្រាយបញ្ហាអ្វីមួយដែលកើតមានឡើង។ កិច្ចសហការរបស់មន្ត្រីរដ្ឋាភិបាលនឹងជួយឲ្យស្ថាប័ននីតិបញ្ញត្តិទទួលបានព័ត៌មានច្បាស់លាស់គ្រប់ជ្រុងជ្រោងពីមន្ត្រីអនុវត្តនការងារផ្ទាល់ ប៉ុន្តែវាមិនមានន័យថាមន្ត្រីទាំងនោះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរដ្ឋសភានោះទេ។